ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានា រ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនស្ហួរេន ម.ក

THE BENEFITS RECEIVED FROM LIFE INSURANCE

FORTUNE LIFE INSURANCE PLC

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក

THE BENEFITS RECEIVED FROM LIFE INSURANCE
FORTUNE LIFE INSURANCE PLC

គ្រូណែនាំ៖ សោម ស៊ីវគា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សោម ស៊ីវគា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យ វ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យ វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំ សម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយ ស្តីពី **"អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៍រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក"** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការធ្វើម៉ាឃីតធីង។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណាមួយនេះឡើង នឹងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែល មានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**សំ សិលា**
ID: B22/283



**ឆាយ ក្យ្រា**
ID: B22/228



**ឡេង ដារ៉ែន**
ID: B22/1447



**ម៉េត តារៈ**
ID: B22/1519



**ស្រេង ម៉ីម៉ី**
ID: B22/1535

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យ វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្តាសាស្រ្តាចារ្យ  លោកគ្រូអ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាល័យធិការនៃសាកលវិទ្យាល័យ វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។ សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **សោម ស៊ីវគា** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្រ្តាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យ វ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី "**អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៍រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក**" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវ ដែលបានលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ..ចន្ទ..៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី.២៧. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

សំ សិលា

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

បើពិនិត្យមើលលើស្ថានភាពជាក់ស្តែងនៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះសង្កេតឃើញថាមានការកើនឡើងជាខ្លាំងក្លា គួរឲ្យកត់សម្គាល់លើវិស័យធានារ៉ាប់រងក៏ដូចជាវិស័យហិរញ្ញវត្ថុដែលជាហេតុធ្វើឱ្យមានការប្រកួតប្រជែងគ្នាជាខ្លាំងតាមរយៈសេវាកម្ម និងផលិតកម្មទៅតាមក្រុមហ៊ុននីមួយៗ។ កត្តានេះហើយដែលធ្វើឱ្យម្ចាស់ជីវកម្មតាមបណ្តាក្រុមហ៊ុនធានារ៉ាប់រងមានការយល់ដឹងកាន់តែខ្លាំង និងយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាកម្មធានារ៉ាប់រងជូនអតិថិជន ក៏ដូចជាការការពារជូនអតិថិជននូវការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវតាមស្តង់ដារដែលបានកំណត់ ពិសេសធ្វើយ៉ាងណាឱ្យការធានារ៉ាប់រងមានប្រសិទ្ធភាពខ្ពស់ជូនអតិថិជន និងមានទំនុកចិត្តខ្ពស់។

យោងទៅតាមការស្រាវជ្រាវតាមប្រព័ន្ធវេបសាយ ការស្រាវជ្រាវនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យ និងការចុះទៅយកទិន្នន័យដោយផ្ទាល់នៅក្រុមហ៊ុនជាច្រើនខែកន្លងមកនេះ ក្រុមយើងខ្ញុំទទួលបានសមិទ្ធផលគួរជាទីគាប់ចិត្តដូចជា ប្រវត្តិពង្សាវតានៃក្រុមហ៊ុន គុណសម្បត្តិ និងគុណវិបត្តិនៃការផ្តល់ជូនអតិថិជននូវសេវាធានារ៉ាប់រងអាយុជីវិត និងសារៈសំខាន់នៃការទិញកញ្ចប់ធានារ៉ាប់រង រួមជាមួយអត្ថប្រយោជន៍ជាច្រើនទៀត។ កត្តាដែលជំរុញឱ្យអតិថិជនប្រើប្រាស់សេវាធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព ក៏ដូចជាយល់ដឹងកាន់តែជាក់ច្បាស់អំពីលក្ខខណ្ឌតម្រូវមុនពេលសម្រេចចិត្តទិញកញ្ចប់សេវាធានារ៉ាប់រង។ ដោយផ្អែកតាមការចុះទៅផ្ទាល់នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក ក្រុមយើងខ្ញុំសង្កេតឃើញថាក្រុមហ៊ុន មានការប្រឹងប្រែងជាខ្លាំងក្នុងការរិះរកនូវមធ្យោបាយយ៉ាងណាដើម្បីពន្យល់ទៅកាន់អតិថិជនរបស់ខ្លួន ឱ្យយល់ច្បាស់អំពីលក្ខខណ្ឌមុននឹងត្រូវទូទាត់សំណង ដើម្បីជៀសវាងរាល់ការភាន់ច្រឡំដែលអាចកើតមានចំពោះផលិតផល និង សេវាកម្មរបស់ក្រុមហ៊ុនផ្ទាល់។

ក្រោយការខិតខំប្រឹងប្រែងស្រាវជ្រាវយ៉ាងលម្អិតអំពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ ក្រុមយើងខ្ញុំបានទទួលលទ្ធផលជាផ្លែផ្កាដើម្បីចងក្រងរៀបចំឯកសារស្រាវជ្រាវមួយច្បាប់ទុកជូនលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងគណៈកម្មការផងដែរ។ សរុបរួមមកយើងអាចនិយាយបានថា គ្មានអ្វីដែលល្អឥតខ្ចោះនោះទេ រមែងតែងតែមានចំណុចខ្វះខាតដែលជៀសមិនផុតនោះឡើយ អ្វីដែលក្រុមយើងខ្ញុំកត់សម្គាល់ឃើញនោះគឺថា អតិថិជននៅកម្ពុជាភាគច្រើនមិនទាន់មានទំនុកចិត្តក្នុងការប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតយ៉ាងទូលំទូលាយនៅឡើយនោះទេ ព្រោះពួកគេនៅមានផ្នត់គំនិតថា ការទិញសេវាធានារ៉ាប់រង គឺជាការប្រមាថអាយុជីវិតរបស់ខ្លួន។ ជាដំណោះស្រាយក្រុមយើងខ្ញុំបានលើកឡើងនៅជំពូកទី៥ គឺការពន្យល់ទៅកាន់សំណាក់អតិថិជន ដើម្បីឱ្យពួកគេមានទំនុកចិត្តក្នុងការប្រើប្រាស់សេវាកម្មដោយស្ងប់ចិត្ត ដោយផ្អែកទៅលើ កេរ្តិ៍ឈ្មោះ ទីតាំងច្បាស់លាស់ ដៃគូរសហការណ៍ដែលមានការផ្សព្វផ្សាយ បណ្តុះបណ្តាលបុគ្គលិកយ៉ាងស្ទាត់ជំនាញ និងមានប្រវត្តិធ្លាប់ទូទាត់សំណងទៅកាន់អតិថិជនផ្ទាល់របស់ក្រុមហ៊ុន ប្រកបដោយសេចក្តីទុកចិត្តទៅកាន់ក្រុមហ៊ុន។

# មាតិកា

ទំព័រ

អារម្ភកថា ..... i
រចនាសម្ព័នក្រុម ..... ii
សេចក្តីថ្លែងអំណរគុណ ..... iii
អំណះអំណាង ..... iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ..... v
មាតិការ ..... vi

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ..... ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ២
    ១.៤.១ ទំហំដែនកំណត់ ..... ២
    ១.៤.២ វិសាលភាព ..... ២
១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ..... ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣
    ១.៦.១ សម្រាប់អ្នកស្រាវជ្រាវ ..... ៣
    ១.៦.២ សម្រាប់ស្ថាប័ន ..... ៣
    ១.៦.៣ សម្រាប់សង្គមជាតិ ..... ៤
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៥

## ជំពូកទី២
## អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាកម្មធានារ៉ាប់រងអាយុជីវិត

២.១ លក្ខណៈទូទៅនៃសេវាធានារ៉ាប់រង ..... ៦
    ២.១.១ និយមន័យនៃសេវាធានារ៉ាប់រង ..... ៦
    ២.១.២ ប្រវត្តិនៃសេវាធានារ៉ាប់រង ..... ៦
    ២.១.៣ សេវាធានារ៉ាប់រង ..... ៧
២.២ កត្តាដែលជំរុញឱ្យអតិថិជនប្រើប្រាស់សេវាកម្ម របស់ក្រុមហ៊ុនធានារ៉ាប់រង ..... ៩
    ២.២.១ និយមន័យសេវាកម្ម ..... ៩
    ២.២.២ ប្រវត្តិសេវាកម្ម ..... ៩
    ២.២.៣ សេវាកម្ម ..... ៩
២.៣ លក្ខខណ្ឌតម្រូវមុនពេលដែលប្រើប្រាស់សេវាកម្មធានារ៉ាប់រងរបស់អតិថិជន ..... ១០

២.៣.១ និយមន័យលក្ខខណ្ឌ ............ ១០
២.៣.២ ប្រវត្តិលក្ខខណ្ឌ ............ ១០
២.៣.៣ លក្ខខណ្ឌ ............ ១០
២.៤ លក្ខខណ្ឌដែលក្រុមហ៊ុនធានារ៉ាប់រងបដិសេធទូទាត់សំណងជូនអតិថិជន ............ ១១
២.៤.១ និយមន័យសំណង ............ ១១
២.៤.២ ប្រវត្តិសំណង ............ ១២
២.៤.៣ សំណង ............ ១២

## ជំពូកទី៣
## អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក

៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក ............ ១៤
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន ............ ១៤
៣.១.២ និមិត្តសញ្ញារបស់ក្រុមហ៊ុន ............ ១៧
៣.១.៣ ចក្ខុវិស័យ ការប្តេជ្ញាចិត្ត និងគុណតម្លៃរបស់ក្រុមហ៊ុន ............ ១៧
៣.១.៤ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន ............ ១៨
៣.២ កត្តាដែលជម្រុញឱ្យអតិថិជនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក ............ ១៨
៣.២.១ ផលិតផលរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក ... ១៨
ក. ផលិតផលការសិក្សាជាមួយ ហ្វ៊ូឈ្វេន ឡាយហ្វ៍ ............ ១៨
ខ. ផលិតផលអនាគតគ្រួសារខ្ញុំជាមួយ ហ្វ៊ូឈ្វេន ឡាយហ្វ៍ ............ ១៩
គ. ផលិតផល For Life ចម្រើនទ្រព្យ ............ ១៩
ឃ. ផលិតផលការពារនិយោជិតជាមួយ ហ្វ៊ូឈ្វេន ឡាយហ្វ៍ ............ ១៩
៣.២.២ កត្តាសំខាន់ៗដែលជម្រុញឱ្យអតិថិជនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ............ ២០
៣.៣ លក្ខខណ្ឌតម្រូវរបស់អតិថិជនមុនពេលដែលប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក ............ ២១
៣.៣.១ លក្ខខណ្ឌតម្រូវរបស់អ្នកត្រូវបានធានា (Policyholder) ............ ២១
៣.៣.២ លក្ខខណ្ឌតម្រូវរបស់អ្នកទទួលផល (Beneficiary) ............ ២២
៣.៤ លក្ខខណ្ឌដែលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈ្វេនឡាយហ្វ៍ អ៊ិនសួរេន ម.ក បដិសេធទូទាត់សំណងជូនអតិថិជន ............ ២២
៣.៤.១ ករណីក្រុមហ៊ុនបដិសេធទូទាត់សំណងជន ............ ២២
៣.៤.២ ករណីលើកលែងអត្ថប្រយោជន៍បន្ថែមក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ ............ ២៣

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង........................................................................................ ២៤
៤.២ ការវិភាគលើចំណុចខ្សោយ ..................................................................................... ២៤


## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ....................................................................................................... ២៥
៥.២ ការផ្តល់អនុសាសន៍ ................................................................................................... ២៥

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជាសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់ក្នុងការប្រែក្លាយពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ បើក្រឡេកមើលប្រវត្តិសាស្ត្របន្តិចឃើញថាប្រទេសកម្ពុជាមុននឹងទទួលបានសុខសន្តិភាពពេញលេញដូចបច្ចុប្បន្ន យើងក៏ធ្លាប់ឆ្លងកាត់ ប្រវត្តិសាស្ត្រសង្គ្រាមរ៉ាំរ៉ៃជាច្រើនលើកច្រើនសាររួចមកហើយ។ ការបាត់បង់ទ្រព្យសម្បត្តិជាតិ វប្បធម៌ ទឹកដី ពិសេសគឺធនធានមនុស្សក្នុងរបបប្រល័យពូជសាសន៍ គឺជារូបភាពមួយដែលពិភពលោកឃើញថាពិតជាពិបាកខ្លាំងណាស់ក្នុងការក្រោកចេញពីស្រមោលខ្មៅងងឹតមួយនេះឱ្យមើលឃើញរស្មីនៃភាពរុងរឿងឡើងវិញ។

ក្រោមការដឹកនាំដោយភាពឈ្លាសវៃ និងស្មារតីស្នេហាជាតិ យកចិត្តទុកដាក់ពីអតីតរាជរដ្ឋាភិបាល និងរាជរដ្ឋាភិបាលបច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាកំពុងតែទទួលបានឯករាជ្យភាព ស្ថេរភាពនយោបាយ សន្តិសុខសង្គម និងភាពរីកចម្រើនគ្រប់វិស័យ ពិសេសគឺវិស័យហិរញ្ញវត្ថុដែលជាវិស័យដ៏សំខាន់មួយបង្ហាញឱ្យឃើញកាន់តែច្បាស់ថា ការរីកចម្រើនគឺពិតជាមាននៅក្នុងដែនដីសុវណ្ណភូមិតូចតែសំបូរផ្សរផង់មួយនេះ។

សេវាធានារ៉ាប់រងអាយុជីវិតជាផ្នែកមួយនៃវិស័យហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ដែលបានចូលរួម និងដើរតួនាទីជាផ្នែកមួយយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិថែមមួយកម្រិតទៀតក្នុងរយៈពេលជាងមួយទសវត្សរ៍មកហើយពោលគឺចាប់តាំងពីឆ្នាំ២០១២មកម្ល៉េះ។ ទីក្រុងរណបរីកសាយភាយដុះដាល ជុំវិញរាជធានី ក្រុមហ៊ុនបរទេសជាច្រើនសម្រុកចូលមកវិនិយោគ បូករួមទាំងសហគ្រិនក្នុងស្រុកបានរំលេចខ្លួនឡើងជាបន្តបន្ទាប់ ស្របពេលដែលធនធានមនុស្សខ្មែរជំនាន់ក្រោយមានកាន់តែច្រើន កាន់តែមានគុណភាព ធ្វើឱ្យកំណើននៃតម្រូវការធានារ៉ាប់រងអាយុជីវិត រឹតតែដើរតួយ៉ាងសំខាន់ស្របពេលជាមួយគ្នា។ គ្រោះថ្នាក់ការងារ ជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ដែលបណ្តាលឱ្យប៉ះពាល់ដល់ការរកចំណូលផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ សុទ្ធតែជាអ្វីដែលបុគ្គលទាំងឡាយមិនចង់ជួបប្រទះឡើយគ្រាន់តែថា វាមិនដឹងកើតឡើងនៅពេលណាចំពោះអ្នកណា ក្នុងកាលៈទេសៈបែបណាតែប៉ុណ្ណោះ។ ហេតុនេះហើយទើបធ្វើឱ្យម្ចាស់អាជីវកម្មជាច្រើនបានសម្រេចប្រើប្រាស់សេវាធានារ៉ាប់រងទូទៅ ឬសេវាធានារ៉ាប់រងអាយុជីវិត ជូនដល់និយោជិតរបស់ខ្លួន ឬក៏ប្រើប្រាស់សេវានេះជាលក្ខណៈផ្ទាល់ខ្លួនតែម្តង ដើម្បីធានាឱ្យបាននូវសុវត្ថិភាពហិរញ្ញវត្ថុក្នុងកម្រិតណាមួយឱ្យមានតុល្យភាព ទោះបីជាមានហេតុការអាក្រក់ណាមួយកើតឡើងជាយថាហេតុ ដែលនាំឱ្យប៉ះពាល់ដល់ការរកចំណូល ប្រចាំសេដ្ឋកិច្ចគ្រួសារក៏ដោយ។ ដូចដែលបានឃើញជាក់ស្តែងប្រទេសកម្ពុជាយើងមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតជាច្រើន មានទាំងក្រុមហ៊ុនក្រៅប្រទេស និងក្រុមហ៊ុនក្នុងស្រុក កំពុងមានវត្តមានបម្រើសេវា និងផ្តល់ជូននូវអត្ថប្រយោជន៍ល្អៗជូនដល់អតិថិជនរៀងៗខ្លួន។ ការប្រកួតប្រជែងដ៏សំបូរបែបក្នុងទីផ្សារធំទូលាយមួយនេះ ពិតជាធ្វើឱ្យអតិថិជនមានជម្រើសកាន់តែច្រើនមុននឹងសម្រេចចិត្តជ្រើសរើសប្រើសេវាមួយនេះ។ ហេតុដូច្នេះហើយទើបក្រុមយើងខ្ញុំបានសិក្សា ស្រាវជ្រាវទៅលើប្រធានបទ "**អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតហ្វ៊ូឈូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក**" ដើម្បីជាគំនិតបំភ្លឺបន្ថែមក្នុងការសម្រេចចិត្តប្រើប្រាស់សេវានេះឱ្យបានត្រឹមត្រូវ និងស្របតាមស្ថានភាពជាក់ស្តែងផ្ទាល់ខ្លួនរបស់អតិថិជន។

តាមរយៈឱកាសមួយនេះ ក្រុមយើងខ្ញុំប្តេជ្ញាថានឹងព្យាយាមស្រាវជ្រាវ និងដកស្រង់ព័ត៌មានល្អៗ ច្បាស់ៗ មករំលេចឡើងយ៉ាងលម្អិតនៅក្នុងនិក្ខេបបទមួយនេះ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃនេះដូចដែលយើងបានដឹងស្រាប់ទៅហើយ ថាមានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតជាច្រើនដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា។ នៅក្នុងនោះដែលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈូនឡាយហ្វ៍ ក៏បានឈរជើងជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយ នៅក្នុងចំណោមក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតជាច្រើនដែលមាននៅក្នុងប្រទេស ហើយមានការទទួលស្គាល់ និងការគាំទ្រពីអតិថិជនប្រើប្រាស់សេវាកម្មធានារ៉ាប់រងផងដែរ។ ដើម្បីជាជំនួយ និងបង្ហាញទៅកាន់ប្រជាជនអោយស្គាល់ពីក្រុមហ៊ុនហ្វ៊ូឈូនឡាយហ្វ៍ កាន់តែច្បាស់មួយកម្រិតបន្ថែមទៀតនោះទើបក្រុមយើងខ្ញុំមានសំណួរមួយចំនួនចោទសួរដូចខាងក្រោម៖

១. តើកត្តាអ្វីខ្លះដែលជំរុញឱ្យអតិថិជនប្រើប្រាស់ សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក?

២. តើអតិថិជនត្រូវមានលក្ខខណ្ឌតម្រូវអ្វីខ្លះ មុនពេលដែលប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក?

៣. តើក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក ពិនិត្យទៅលើលក្ខខណ្ឌអ្វីខ្លះចំពោះអតិថិជន មុននឹងធ្វើការបដិសេធទូទាត់សំណង?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីទទួលបាននូវការស្រាវជ្រាវដ៏ល្អមួយ យើងត្រូវយល់ដឹងអំពីគោលបំណង និងការទាមទារចង់បានរបស់កិច្ចការស្រាវជ្រាវនេះជាមុនសិន។ ស្របពេលដែលធ្វើការស្រាវជ្រាវទៅលើប្រធានបទ "អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក" នៅកម្ពុជានេះបានបង្ហាញឱ្យឃើញនូវគោលបំណងសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- កត្តាដែលធ្វើឱ្យមានប្រសិទ្ធភាពទៅលើការពង្រីកសក្តានុពលលើវិស័យធានារ៉ាប់រងអាយុជីវិត
- ដំណើរការនៃការសិក្សាពីអតិថិជន មុនពេលប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិត
- លក្ខខណ្ឌ និង គោលការណ៍ក្នុងការទិញសេវាធានារ៉ាប់រងអាយុជីវិត
- លក្ខខណ្ឌមិនទូទាត់សំណង
- ផលប្រយោជន៍នៃសេវាធានារ៉ាប់រងអាយុជីវិត។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ប្រធានបទស្រាវជ្រាវ គឺលើកយកមកសិក្សាស្រាវជ្រាវតែការធានារ៉ាប់រងអាយុជីវិតរបស់ក្រុមហ៊ុនហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក ដែលមានទីតាំងនៅអគារឌីហ្គេតវេយ៍ ជាន់ទី២៦ មហាវិថីសហព័ន្ធរុស្សី (ផ្លូវ១១០) សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### ១.៤.២ វិសាលភាព

សម្រាប់ទិន្នន័យដែលយកមកបង្ហាញក្នុងការស្រាវជ្រាវនេះ យើងខ្ញុំសូមលើកយកមកបង្ហាញតែការធានារ៉ាប់រងអាយុជីវិត របស់ក្រុមហ៊ុន ហ្វ៊ូឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក ដែលមានការបម្រើសេវាកម្មលើធានា

រ៉ាប់រ៉ងអាយុជីវិតនៅក្នុងប្រទេសកម្ពុជាតែមួយគត់ ក្នុងការសិក្សាស្រាវជ្រាវ គឺកំណត់យកត្រឹមតែឆ្នាំ២០២៤ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសរសេរសារណាក្រុមពួកខ្ញុំជ្រើសរើសយកនូវវិធីសាស្ត្រក្នុងការសរសេរពីតាមបែបគុណវិស័យ និងបរិមាណវិស័យ សម្រាប់រៀបរាប់ពីអត្ថប្រយោជន៍ដែលទទួលបានពីការធានារ៉ាប់រ៉ងអាយុជីវិត។ ការប្រមូលទិន្នន័យធ្វើឡើងដោយផ្អែកលើសំណួរបីដូចមានចែងខាងក្រោម៖

សម្រាប់សំណួរទី១ ពាក់ព័ន្ធទៅនឹងការសិក្សាស្រាវជ្រាវនេះ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ និងបរិមាណវិស័យ ដោយធ្វើឡើងតាមរយៈការចុះសាកសួរព័ត៌មានដោយផ្ទាល់ទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង អាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ ស្រាវជ្រាវបន្ថែមតាមរយៈគេហទំព័រ និងតាមរយៈការស្រាវជ្រាវនៅក្នុងបណ្ណាល័យរបស់សាកលវិទ្យាល័យ វ៉ាន់ដា។

សម្រាប់សំណួរទី២ និងទី៣ ការប្រមូលទិន្នន័យតាមបែបគុណវិស័យ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវ គឺជាការនាំមកនៅភាពរីកចម្រើនដល់និស្សិតក្នុងការផ្លាស់ប្តូរពួកគេឱ្យយល់កាន់តែជាក់ច្បាស់ពីសកម្មភាពក្នុងសង្គម និងទំនាក់ទំនងប្រត្តិបត្តិមួយចំនួននៅក្នុងសង្គមនាពេលបច្ចុប្បន្ននេះ។ សារៈសំខាន់នៃការស្រាវជ្រាវនេះ គឺបានផ្តល់ចំណេះដឹងដល់ក្រុមពួកខ្ញុំដូចជា៖

### ១.៦.១ សម្រាប់អ្នកស្រាវជ្រាវ

សម្រាប់អ្នកស្រាវជ្រាវ វាជាដំណើរការស្វែងយល់ វិភាគ និងបកស្រាយពីបញ្ហា ឬប្រធានបទជាក់លាក់។ នៅពេលបញ្ចប់ការស្រាវជ្រាវ អ្នកស្រាវជ្រាវអាចទទួលបានចំណេះដឹង និងការយល់ដឹងថ្មីៗដូចខាងក្រោម៖

- ការរកឃើញទ្រឹស្តីថ្មី ឬដំណោះស្រាយថ្មីដែលមិនធ្លាប់មានពីមុន។
- ការអនុវត្តន៍ជាក់ស្តែង ដោយយកលទ្ធផលនៃការស្រាវជ្រាវទៅអនុវត្តក្នុងជីវិតជាក់ស្តែង ដូចជាការអភិវឌ្ឍន៍គម្រោង គោលនយោបាយ ឬយុទ្ធសាស្ត្រអាជីវកម្ម។
- ការបង្កើតឱកាសថ្មីៗដោយការស្រាវជ្រាវអាចបើកផ្លូវឱ្យមានការសហការការងារ ឬការអភិវឌ្ឍន៍ជំនាញផ្ទាល់ខ្លួន។
- ការផ្លាស់ប្តូរគំនិត និងទស្សនៈ ដោយអ្នកស្រាវជ្រាវអាចមានការយល់ឃើញខុសពីមុន ឬមានផ្នត់គំនិតថ្មីក្នុងការដោះស្រាយបញ្ហា។
- ការបំពេញចំណុចខ្វះខាត ជារឿយៗការស្រាវជ្រាវជួយឆ្លើយតបទៅនឹងសំណួរដែលមិនទាន់មានចម្លើយ ឬកែលម្អចំណេះដឹងដែលមានស្រាប់។

### ១.៦.២ សម្រាប់ស្ថាប័ន

សម្រាប់ក្រុមហ៊ុន វាជាមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចចិត្ត ការអភិវឌ្ឍន៍ និងការបង្កើតគុណសម្បត្តិនៃការប្រកួតប្រជែង។ ការស្រាវជ្រាវ គឺជាឧបករណ៍សំខាន់ដែលជួយឱ្យក្រុមហ៊ុនធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានពិត កាត់បន្ថយហានិភ័យ និងបង្កើតអត្ថប្រយោជន៍យូរអង្វែង។ ខាងក្រោមនេះ គឺជាសារៈសំខាន់ដែលស្ថាប័នទទួលបានពីការស្រាវជ្រាវ៖

- យល់ដឹងពីទីផ្សារ និងអតិថិជន ដោយការស្រាវជ្រាវទីផ្សារជួយឱ្យក្រុមហ៊ុនយល់ដឹងពីតម្រូវការ ចំណង់ចំណូលចិត្ត និងឥរិយាបថរបស់អតិថិជន។ វាអាចរកឃើញឱកាសថ្មីៗ ឬកែលម្អផលិតផល ឬសេវាកម្មដើម្បីឆ្លើយតបតាមតម្រូវការទីផ្សាររបស់អតិថិជន។
- កាត់បន្ថយហានិភ័យ ការសិក្សាលម្អិតអំពីគម្រោង សក្តានុពលទីផ្សារ ឬបច្ចេកវិទ្យាថ្មីអាចជួយកាត់បន្ថយកំហុសដែលអាចកើតមាន និងផ្តល់ទិន្នន័យជាក់ស្តែងដើម្បីគាំទ្រដល់ការសម្រេចចិត្ត ជំនួសឱ្យការទស្សន៍ទាយ។
- ជំរុញភាពច្នៃប្រឌិត ការស្រាវជ្រាវអាចរកឃើញបច្ចេកវិទ្យា ឬវិធីសាស្ត្រថ្មីៗដើម្បីអភិវឌ្ឍន៍ផលិតផល សេវាកម្ម ឬដំណើរការផ្នែកអាជីវកម្ម ជួយឱ្យក្រុមហ៊ុនឈានមុខគេក្នុងវិស័យរបស់ខ្លួន។
- យល់ពីដៃគូប្រជែង ការវិភាគដៃគូប្រជែងអាចជួយក្រុមហ៊ុនយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ពួកគេ ហើយកែលម្អយុទ្ធសាស្ត្ររបស់ខ្លួន។
- យុទ្ធសាស្ត្រអាជីវកម្មយូរអង្វែង ការស្រាវជ្រាវអាចជួយព្យាករណ៍អនាគត ដូចជាប្រែប្រួលទីផ្សារ ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬអាកប្បកិរិយាអ្នកប្រើប្រាស់ ជួយឱ្យក្រុមហ៊ុនរៀបចំផែនការយូរអង្វែងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។
- ពង្រឹងភាពជាអ្នកដឹកនាំ ក្រុមហ៊ុនដែលផ្តោតសំខាន់លើការស្រាវជ្រាវ អាចមានឱកាសខ្ពស់ក្នុងការក្លាយជាអ្នកដឹកនាំក្នុងវិស័យរបស់ខ្លួន តាមរយៈការបង្កើតផលិតផល ឬសេវាកម្មដែលមានភាពច្នៃប្រឌិត។

**១.៦.៣ សម្រាប់សង្គមជាតិ**

ការស្រាវជ្រាវមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអភិវឌ្ឍន៍សង្គម ដោយអាចផ្តល់អត្ថប្រយោជន៍ជាច្រើន វាមិនត្រឹមតែជួយដោះស្រាយបញ្ហាបច្ចុប្បន្នប៉ុណ្ណោះទេ ថែមទាំងជួយរៀបចំអនាគតដ៏ល្អប្រសើរជាងមុនសម្រាប់សង្គមជាតិ៖

- ការអភិវឌ្ឍសេដ្ឋកិច្ច អាចជំរុញភាពច្នៃប្រឌិត បង្កើតឧស្សាហកម្មថ្មីៗ និងលើកកំពស់ផលិតភាពដែលនាំឱ្យមានការកើនឡើងនៃសេដ្ឋកិច្ច។
- ការដោះស្រាយបញ្ហាសង្គម អាចជួយវិភាគ និងផ្តល់ដំណោះស្រាយចំពោះបញ្ហាសង្គមដូចជា ភាពក្រីក្រ ជម្ងឺរាតត្បាត ឬការប្រែប្រួលអាកាសធាតុ។
- ការលើកកម្ពស់យុត្តិធម៌ និងសមភាពសង្គម អាចជួយឱ្យមានការយល់ដឹងអំពីវិសមភាពសង្គម និងជំរុញយុត្តិធម៌សង្គម។
- ជំរុញការផ្សព្វផ្សាយវប្បធម៌ អាចរក្សានិងបង្ហាញនូវអត្តសញ្ញាណជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ និងស្នាដៃមនុស្សជាតិ។
- ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ អាចជំរុញកិច្ចសហការរវាងប្រទេស ដោយចែករំលែកចំណេះដឹង និងបច្ចេកវិជ្ជា។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកចេញជា៥ជំពូក ដូចខាងក្រោម៖

- **ជំពូកទី១៖** លំនាំបញ្ហានៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវដើម្បីធ្វើការកំណត់បញ្ហាឱ្យបានច្បាស់លាស់ទាក់ទងនឹងប្រធានសារណា។ ស្វែងរក និងពង្រីកចំណេះដឹងថ្មី ដែលមាននៅក្នុងវិស័យធានារ៉ាប់រង ដើម្បីដោះស្រាយបញ្ហារបស់សង្គមជាតិក្នុងគោលបំណងអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរឡើងឈានដល់ការរីកចម្រើនរាល់គ្រប់វិស័យ។
- **ជំពូកទី២៖** បង្ហាញពីលក្ខណៈទូទៅរបស់សេវាកម្មធានារ៉ាប់រង ក៏ដូចជាប្រវត្តិសេវាធនារ៉ាប់រងដើម្បីបង្កើតជានិយមន័យក៏ដូចជាសារៈសំខាន់នៃសេវាធានារ៉ាប់រង ប្រភេទនៃសេវាធានារ៉ាប់រងជាដើម។ បកស្រាយទៅលើនិយមន័យ ប្រវត្តិ និងទ្រឹស្តី ចំពោះពាក្យគន្លឹះក្នុងសំនួរទាំង៣ ដែលបានចោទសួរដើម្បីមានភាពងាយស្រួលមុននឹងឈានទៅដល់ការបកស្រាយលម្អិតទាក់ទងទៅនឹងសំនួរ។
- **ជំពូកទី៣៖** និយាយអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន ជីវប្រវត្តិក្រុមហ៊ុន រចនាសម្ព័ន្ធរបស់ក្រុមហ៊ុនក៏ដូចជាទស្សនវិស័យ និងអត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈុន ឡាយហ្វ៍ អ៊ិនសួរេន ម.ក។ បកស្រាយយ៉ាងលម្អិតនូវសំនួរដែលបានចោទសួរដោយធ្វើឡើងតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបរិមាណវិស័យ។
- **ជំពូកទី៤៖** ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយ។
- **ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

# ជំពូកទី២
# អត្ថប្រយោជន៍នៃការប្រើប្រាស់សេវាកម្មធានារ៉ាប់រងអាយុជីវិត

## ២.១ លក្ខណៈទូទៅនៃសេវាធានារ៉ាប់រង

### ២.១.១ និយមន័យនៃសេវាធានារ៉ាប់រង

សេវាធានារ៉ាប់រង សំដៅដល់ការធ្វើកិច្ចសន្យាធានារ៉ាប់រងក្នុងនោះអ្នកត្រូវបានធានារ៉ាប់រងត្រូវបានបង់បុព្វលាភធានារ៉ាប់រងឲ្យទៅក្រុមហ៊ុនធានារ៉ាប់រងហើយក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើ សំណង ដល់ការខូតខាត ឬការបាត់បង់ទ្រព្យសម្បត្តិដែលបង្កឡើងដោយ ហេតុការណ៍គ្រោះថ្នាក់ឬក៏ធ្វើសំណងនៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងស្លាប់ របួស ពិការ មានជំងឺ ឬនៅពេលដែលបុគ្គលនោះឈានដល់កាលកំណត់ណាមួយដែលភាគីទាំងពីរបានព្រមព្រៀងគ្នាដូច មានចែងក្នុងកិច្ចសន្យាធានារ៉ាប់រង។ សេវាធានារ៉ាប់រងអាយុជីវិត គឺជាផលិតផលហិរញ្ញវត្ថុដ៏សំខាន់ដែលជួយការពារបុគ្គល និងក្រុមគ្រួសាររបស់អ្នកពីហានិភ័យផ្សេងៗ។ វាគឺជាកិច្ចព្រមព្រៀងដែលធ្វើឡើងរវាងអ្នកធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ដែលអ្នកធានារ៉ាប់រងយល់ព្រមធ្វើការបង់ប្រាក់បុព្វលាភជាប្រចាំជាថ្នូរនឹងការធានារ៉ាប់រងលើហានិភ័យមួយចំនួន។ ហានិភ័យទាំងនេះអាចរួមបញ្ចូលទៅលើករណីមរណៈភាពគ្រោះថ្នាក់ផ្ទាល់ខ្លួន ជំងឺធ្ងន់ធ្ងរ ឬជំងឺទូទៅ ដែលមានចែងនៅក្នុងខ និងលក្ខខណ្ឌកិច្ចសន្យាធានារ៉ាប់រង[1]។

សេវាធានារ៉ាប់រង គឺជាការផ្ទេរហានិភ័យនៃការបាត់បង់ដែលកើតឡើងជាលទ្ធផលនៃព្រឹត្តិការណ៍ដាក់លាក់ឬមិនបានមើលឃើញទុកជាមុនត្រូវបានផ្ទេរពីបុគ្គលឬអង្គការទៅក្រុមហ៊ុនធានារ៉ាប់រងជាថ្នូរនឹងថ្លៃធានា។ ប្រសិនបើមានព្រឹត្តិការណ៍ជាក់លាក់កើតឡើងបុគ្គលឬអង្គការដែលធានារ៉ាប់រងអាចទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រង ក្នុងន័យនេះការធានារ៉ាប់រងពិតជាវិធីមួយដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជា។ គោលការណ៍ធានារ៉ាប់រងដែលបានទិញសម្រាប់បុព្វលាភតូចលុបបំបាត់លទ្ធភាពការបាត់បង់កាន់តែច្រើន[2]។

### ២.១.២ ប្រវត្តិនៃសេវាធានារ៉ាប់រង

គំនិតនៃការធានារ៉ាប់រងមានតាំងពីឆ្នាំ ១៧៥០ មុនគ.ស ដោយព្រះរាជគំនិតរបស់ស្តេច Hammurabi នៃអាណាចក្របាប៊ីឡូនមកម្ល៉េះ ដោយអ្នកវិទ្យាសាស្ត្របានធ្វើរបកគំហើញក្នុងវិមានថ្ម និងបន្ទះដីឥដ្ឋជាច្រើននៅស្ថាននីយ៍កំណាយបាប៊ីឡូនបុរាណ។ ផ្តើមចេញពីសកម្មភាពដែលទំនិញរបស់កប៉ាល់អាចត្រូវបានសន្យាជាថ្នូរនឹងប្រាក់កម្ចី។ ការសងប្រាក់កម្ចីគឺអាស្រ័យទៅលើការធ្វើដំណើរប្រកបដោយជោគជ័យ ហើយកូនបំណុលមិនចាំបាច់សងប្រាក់កម្ចីវិញទេ ប្រសិនបើកប៉ាល់ត្រូវបានបាត់បង់នៅសមុទ្រ។

ការធានារ៉ាប់រងអាយុជីវិតបានចាប់ផ្តើមលេចឡើងនៅសតវត្សទី១៦ និងទី១៧ នៅក្នុងប្រទេសអង់គ្លេស បារាំង និងហូឡង់។ គោលនយោបាយធានារ៉ាប់រងអាយុជីវិតដែលគេស្គាល់ដំបូងគេនៅក្នុងប្រទេសអង់គ្លេសត្រូវបានចេញនៅឆ្នាំ១៥៨៣ ប៉ុន្តែដោយខ្វះវិធីសាស្ត្រដើម្បីវាយតម្លៃហានិភ័យដែលពាក់ព័ន្ធបានត្រឹមត្រូវ ទើបបណ្តាលឱ្យសេវាមួយនេះបានបរាជ័យនៅឡើយ។ ការធានារ៉ាប់រងអាយុជីវិតបានចាប់ផ្តើមផ្លាស់ប្តូរកាន់តែប្រសើរនៅ ឆ្នាំ១៦៩៣ នៅពេលដែលតារាវិទូ និងគណិតវិទូ លោក Edmund Halley

---

[1] Ecoinsoft Solution (20-Jul 2023): https://www.linkedin.com/pulse/%E1%9E%8F%E1%9E%A2%E1%9E%9C%E1%9E%91%E1%9E%87-%E1%9E%80%E1%9E%9A%E1%9E%92%E1%9E%93%E1%9E%9A%E1%9E%94%E1%9E%9A%E1%9E%84-ecoinsoft

[2] EUROLAB Laboratory Inc.(2020): https://www.denetim.com/km/hizmetler/diger-hizmetler/sigorta/

បានសិក្សាពីកំណត់ត្រាកំណើត និងការស្លាប់នៅទីក្រុង Breslau ក្នុងគោលបំណងគណនាតម្លៃនៃអាយុជីវិត។ នេះបណ្តាលឱ្យមានការប្រើប្រាស់តារាងអត្រាមរណៈនៅក្នុងឧស្សាហកម្មធានារ៉ាប់រងអាយុជីវិត។ ចំណែកឯនៅសហរដ្ឋអាមេរិកវិញ ការធានារ៉ាប់រងអាយុជីវិតបានចាប់ផ្តើមបន្តិចម្តងៗចាប់តាំងពីឆ្នាំ១៦០៩ និងត្រូវបានឆ្លងកាត់ការវិវត្តន៍ឱ្យមានការរីកចម្រើនឡើងអស់ជាង១០០ឆ្នាំ ពោលគឺនៅឆ្នាំ១៧៥០ បាននាំមកនូវភាពចាស់ទុំទាំងក្នុងការអនុវត្ត និងគោលនយោបាយដែលបានបង្កើតឡើងក្នុងអំឡុងពេលដូចគ្នានៃពេលវេលានៅអឺរ៉ុប[3]។

រហូតមកដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ គឺជាពេលវេលាមួយដែលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតលំដាប់អន្តរជាតិដំបូងគេបង្អស់មួយបានលេចវត្តមានជាផ្លូវការដំបូងបង្អស់នៅកម្ពុជា[4]។



**២.១.៣ សេវាធានារ៉ាប់រង**

ទីផ្សារធានារ៉ាប់រងនៅកម្ពុជា ចាប់ផ្តើមមានវត្តមាននៅឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ន មានគ្រឹះស្ថានធានារ៉ាប់រងចំនួន៩៤ ដែលក្នុងនោះមានក្រុមហ៊ុនធានារ៉ាប់រងទូទៅ១៨ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត១៤ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច៧ ក្រុមហ៊ុនធានារ៉ាប់រងបន្ត១ ក្រុមហ៊ុនជើងសាធានារ៉ាប់រងចំនួន១៨ ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន៣៤ និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងចំនួន២ កំពុងប្រតិបត្តិការ[5]។

ក. ការធានារ៉ាប់រងទូទៅ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង ដែលក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈកិច្ចទទួលខុសត្រូវ និងសុខភាព។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅមានការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈកិច្ចទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព។

ខ. ការធានារ៉ាប់រងអាយុជីវិត ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងដែលក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាទៅលើការស្លាប់ ឬការរស់រានមានជីវិតដែលអាចរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជំងឺធ្ងន់ធ្ងរ ឬជំងឺទូទៅ។ ការធានា

[3] Investopedia (August 21, 2023): https://www.investopedia.com/articles/08/history-of-insurance.asp
[4] Manulife (September,2023): https://www.manulife.com.kh/km/about-us/our-story/our-brand.html
[5] Ministry of Information (July 27, 2022): https://www.information.gov.kh/articles/81641

រ៉ាប់រងអាយុជីវិតមាន ការធានារ៉ាប់រងមានដែនការកំណត់ ការធានារ៉ាប់រងមួយអាយុកាល ការធានារ៉ាប់រងទាយជ្ជទាន និងការធានារ៉ាប់រងធនលាភ។

គ. ការធានារ៉ាប់រងបន្ត ជាកិច្ចប្រតិបត្តិការធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងដើម ត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀត ដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្តនូវហានិភ័យមួយផ្នែក ឬទាំងស្រុងដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង។

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមនៅតែទទួលខុសត្រូវដដែលចំពោះអ្នកត្រូវបានធានារ៉ាប់រង។

ឃ. ការធានារ៉ាប់រងខ្នាតតូច ជាការផ្តល់កិច្ចសន្យាធានារ៉ាប់រងដល់ប្រជាពលរដ្ឋដែលមានចំណូលទាប ដូចជាការធានារ៉ាប់រងខ្នាតតូចលើទ្រព្យសម្បត្តិ ការធានារ៉ាប់រងខ្នាតតូចលើអាយុជីវិត ការធានារ៉ាប់រងខ្នាតតូចលើរូបរាងកាយ។

ង. ក្រុមហ៊ុនជើងសាធានារ៉ាប់រង ជានីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រងផ្តល់ជាសេវាព្រឹក្សា ផ្តល់ព័ត៌មានទាក់ទងនឹងប្រភេទធានារ៉ាប់រង លក្ខខណ្ឌ និងបុគ្គលិកនៃកិច្ចសន្យាធានារ៉ាប់រង ធ្វើការចរចានិងរៀបចំកិច្ចសន្យាធានារ៉ាប់រងរវាងម្ចាស់សុំការធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង និងលក់បណ្ណសន្យាធានារ៉ាប់រងដោយទទួលពីក្រុមហ៊ុនធានារ៉ាប់រងនូវកម្រៃជើងសាស្របច្បាប់។

ច. ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលជួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រង ធ្វើការណែនាំអំពីការលក់បានសន្យារ៉ាប់រង ការរៀបចំកិច្ចសន្យាធានារ៉ាប់រង ការប្រមូលបុព្វលាភ ការរៀបចំការធ្វើសំណងជាដើម ក្នុងក្របខណ្ឌកំណត់ច្បាស់លាស់នៃកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងដោយទទួលកម្រៃជើងសារពីក្រុមហ៊ុននោះ។

ឆ. ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ជានីតិបុគ្គលឯករាជ្យដែលមានភារកិច្ចត្រួតពិនិត្យផ្ទៀងផ្ទាត់ វាយតម្លៃលើការខូចខាត នៅពេលដែលមានហានិភ័យធានារ៉ាប់រងកើតឡើង និងសម្រេចចេញនូវឯកសារស្តីពីការវាយតម្លៃការខូចខាត សម្រាប់ជាមូលដ្ឋានឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយសំណង។ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលត្រួតពិនិត្យពីក្រុមហ៊ុនធានារ៉ាប់រងតាមកិច្ចព្រមព្រៀង[6]។

[6] INSURANCE REGULATOR OF CAMBODIA (November 02, 2021): https://irc.gov.kh/article?post=7c09d33b-1992-4954-8653-c099663ba779 (មាត្រា២៣, ២៦, ៣២, ៣៩, ៤៦ )

## ២.២ កត្តាដែលជំរុញឱ្យអតិថិជនប្រើប្រាស់សេវាកម្ម របស់ក្រុមហ៊ុនធានារ៉ាប់រង

### ២.២.១ និយមន័យសេវាកម្ម

**សេវាកម្ម** ជាប្រព័ន្ធរដ្ឋាភិបាល ឬអង្គការឯកជនដែលទទួលខុសត្រូវចំពោះប្រភេទសកម្មភាពជាក់លាក់មួយ ឬសម្រាប់ការផ្តល់វត្ថុជាក់លាក់ដែលមនុស្សត្រូវការ[7]។

**សេវាកម្ម** គឺជាសកម្មភាព ឬការប្រើប្រាស់ដែលអ្នកប្រើប្រាស់ ក្រុមហ៊ុន ឬរដ្ឋាភិបាលសុខចិត្តបង់ប្រាក់។ ឧទាហរណ៍រួមមានការងារដែលធ្វើដោយជាងកាត់សក់ វេជ្ជបណ្ឌិត មេធាវី មេកានិក ធនាគារ ក្រុមហ៊ុនធានារ៉ាប់រងជាដើម។ សេវាសាធារណៈ គឺជាសេវាកម្មដែលសង្គម (រដ្ឋជាតិ សហជីពសារពើពន្ធ ឬតំបន់) ទាំងមូលចំណាយសម្រាប់ការប្រើប្រាស់ធនធាន ជំនាញ ភាពប៉ិនប្រសប់ និងបទពិសោធន៍ អ្នកផ្តល់សេវាផ្តល់អត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់សេវាកម្ម។ សេវាកម្មអាចត្រូវបានកំណត់ថាជាសកម្មភាពអរូបី ឬការសម្តែងដែលក្រុមហ៊ុនផ្តល់សេវាផ្តល់តម្លៃដល់អតិថិជន[8]។

### ២.២.២ ប្រវត្តិសេវាកម្ម

ពុំឃើញមានក្នុងវនានុក្រមខ្មែរទេ ប៉ុន្តែតាមការស្រាវជ្រាវរបស់ wikipedia.org ពាក្យថា សេវា គឺជាពាក្យចេញពីភាសាអង់គ្លេស ឬភាសាបារាំង។ ចំណែកពាក្យខ្មែរវិញ គឺប្រហែលជាចេញពីពាក្យ សេវក,សេវកៈ ឬ សេវ៉ក ដែលមានន័យថា អ្នកបម្រើ, អ្នកចាំទទួលបម្រើ, អ្នកគាល់បម្រើ, បរិវារ។ សូមមើលក្នុងពាក្យ វេកជន, សេវកាមាត្រ ទៀតផង។ ពាក្យនេះក៏ឃើញមាននៅក្នុងវចនានុក្រមខ្មែរ ក្នុងពាក្យ បច្ឆាបរិចាកិច្ច បានបកប្រែចេញពី ភាសាបារាំង ដែលមានន័យថា កិច្ចបម្រើក្នុងពេលក្រោយ។ ដូច្នេះ បើយើងស្វែងរកប្រភពដើមនៃពាក្យនេះ ជាភាសាខ្មែរ ខ្ញុំជឿថាវាប្រហែលជាចេញមកអំពីពាក្យ សេវក ដែលមានន័យថា ការបម្រើ ឬ កិច្ចបម្រើ ម្ល៉ោះ ហើយបើសិនយើងបន្ថែម កម្ម មកទៀត ដែលក៏ជានាមកិរិយា ស័ព្ទបញ្ជាក់ អំពី,ការធ្វើ,ដំណើរ ដែរនោះ ពិតជាមាននាមរហូតដល់ពីរ។ បើយើងចង់ប្រើជាពហុវចនៈ យើងអាចថែមពាក្យ នានា, ទាំងឡាយ, ឬទាំងពួង ទើបប្រសើរត្រឹមត្រូវតាមភាសាខ្មែរយើង។ រីឯបើយើងពិនិត្យមើលក្នុងវចនានុក្រម អង់គ្លេស ខ្មែរ វិញ យើងឃើញមានបកប្រែតែមួយកន្លែងគត់ គឺបានបកប្រែថា សេវាយោធា ដែលអាចបកប្រែថាជា ការបម្រើយោធា ឬ ធ្វើយោធា[9]។

### ២.២.៣ សេវាកម្ម

សម្រាប់ការអភិវឌ្ឍន៍ទ្រឹស្តីនៃសេវាកម្ម គឺផ្តោតលើការស្ថាបនាសេវាកម្ម។ ទ្រឹស្តីនេះត្រូវបានពង្រីកដើម្បីរួមបញ្ចូលនូវគំរូអាជីវកម្មផ្សេងៗនៃសេវាកម្ម និងការជួបប្រទះសេវាកម្មដែលរួមមាន ប៉ុន្តែមិនកំណត់ចំពោះការពេញចិត្តរបស់ភ្ញៀវ គុណភាពសេវាកម្ម សេវាកម្ម និងបច្ចេកវិទ្យា ការរចនាប្រព័ន្ធសេវាកម្ម និងការគ្រប់គ្រងទំនាក់ទំនងអតិថិជន។ ទ្រឹស្តីបានចាប់ផ្តើមជាមួយនឹងភាពខុសគ្នាដែលបានសង្កេតឃើញនៅក្នុងការកំណត់សេវាកម្មផ្សេងៗគ្នា ការលេចឡើងនៃបច្ចេកវិទ្យា និងការកំណត់បទពិសោធន៍សេវាកម្មនៅទូទាំងវិស័យជាច្រើន។ ការពិចារណាបន្ថែមទៀតគឺត្រូវបានផ្តល់ទៅឱ្យទិដ្ឋភាពនៃប្រតិបត្តិការសេវាកម្ម និងអ្វីដែលជាសេវាកម្ម ដែលជាតុផ្សំការងារនៃផលិតផលរបស់ក្រុមហ៊ុនត្រូវបានផ្ទេរទៅឱ្យអតិថិជន។ ចុងក្រោយ សេវាកម្ម

[7] Cambridge Dictionary: https://dictionary.cambridge.org/dictionary/english/service
[8] Wikipedia (August 2023): https://en.wikipedia.org/wiki/Service_(economics)
[9] Wikipedia (November 23, 2021): https://km.wikipedia.org/wiki/%E1%9E%9F%E1%9F%81%E1%9E%9C%E1%9E%B6%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98

ខ្លួនឯង និងស្វ័យប្រវត្តិកម្មត្រូវបានពិចារណាក្នុងបរិបទនៃបទពិសោធន៍អ្នកប្រើប្រាស់។ ផលប៉ះពាល់សម្រាប់កម្មវិធីឧស្សាហកម្មត្រូវបានពិភាក្សា[10]។

## ២.៣ លក្ខខណ្ឌតម្រូវមុនពេលដែលអតិថិជនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត

### ២.៣.១ និយមន័យលក្ខខណ្ឌ

**លក្ខខណ្ឌ** គឺជាអ្វីដែលត្រូវបានប្រើនៅក្នុងកិច្ចព្រមព្រៀងជាច្រើន។ ពួកគេក៏មានកាតព្វកិច្ចផងដែរ ប្រសិនបើភាគីម្ខាងទៀតមិនបានអាន ប៉ុន្តែពួកគេមិនត្រូវធ្វើជាមនុស្សដែលមិនសមហេតុផលឡើយ[11]។

**លក្ខខណ្ឌ** គឺជាព្រឹត្តិការណ៍ដែលកើតឡើងនាពេលអនាគតហើយមិនទៀតទាត់(កថាខណ្ឌទី២ នៃមាត្រា៣២៥ នៃក្រមរដ្ឋប្បវេណី)។ ប្រសិនបើព្រឹត្តិការណ៍មួយប្រាកដជាកើតឡើង ព្រឹត្តិការណ៍នោះមិនអាចក្លាយជាលក្ខខណ្ឌទេ[12]។

### ២.៣.២ប្រវត្តិលក្ខខណ្ឌ

**លក្ខខណ្ឌ** ត្រូវបានបង្កើតឡើងតាមរបៀបដែលពួកគេអាចត្រូវបានប្រើសម្រាប់កិច្ចសន្យាជាច្រើន។ ឧទាហរណ៍ ផ្លាស់ប្តូរក្នុងរយៈពេល៨ថ្ងៃដោយមានបង្កាន់ដៃ។ ជាគោលការណ៍នេះអាចអនុវត្តចំពោះអតិថិជនណាមួយ។ ដូច្នេះបទប្បញ្ញត្តិនេះគឺសមស្របសម្រាប់ការដាក់បញ្ចូលក្នុងលក្ខខណ្ឌទូទៅ។

**លក្ខខណ្ឌ** ត្រូវបានអនុវត្តយ៉ាងឆាប់រហ័សដោយអ្នកប្រើមិនចាំបាច់អានវាជាមុនឬធ្វើការចរចារជាមួយភាគីផ្សេងទៀតឡើយទោះបីជាអ្នកប្រើដឹងថាភាគីផ្សេងទៀតមិនបានអានលក្ខខណ្ឌទូទៅក៏ដោយ ក៏ភាគីម្ខាងទៀតនៅតែត្រូវបានគេភ្ជាប់ទៅនឹងវាដែរ ក៏ប៉ុន្តែភាគីនោះត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មាន។ លក្ខខណ្ឌត្រូវបានអនុវត្តតែប្រសិនបើអ្នកប្រើបានផ្តល់ជូនភាគីផ្សេងទៀតនូវឱកាសសមហេតុផលដើម្បីឱ្យគេស្គាល់លក្ខខណ្ឌនោះដែលអាចធ្វើទៅបានតាមបីវិធី:

- អ្នកប្រើអាចប្រើភាគីផ្សេងទៀតមុនពេល ឬនៅចុងបញ្ចប់នៃកិច្ចព្រមព្រៀងផ្តល់នូវលក្ខខណ្ឌទូទៅ។
- មុននឹងបញ្ចប់កិច្ចព្រមព្រៀងអ្នកប្រើអាចប្រាប់ទៅភាគីផ្សេងទៀតថាលក្ខខណ្ឌអាចរកបានសម្រាប់ការត្រួតពិនិត្យ។
- ជាមួយនឹងកិច្ចព្រមព្រៀងអេឡិចត្រូនិចមួយ (ដូចជាការទិញពីចម្ងាយ) អ្នកប្រើមិនគ្រាន់តែបង្កើតលក្ខខណ្ឌទូទៅនិងលក្ខខណ្ឌអេឡិចត្រូនិកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាថា ភាគីផ្សេងទៀតអាចរក្សាទុកលក្ខខណ្ឌទូទៅ[13]។

### ២.៣.៣ លក្ខខណ្ឌ

ទ្រឹស្តីនៃការរៀនតាមលក្ខខណ្ឌ ពិពណ៌នាអំពីទម្រង់នៃការរៀន ដែលការរៀនកើតឡើងជាលទ្ធផលនៃការភ្ជាប់លក្ខខណ្ឌ ឬរំញោចជាមួយនឹងប្រតិកម្ម ឬការឆ្លើយតបជាក់លាក់មួយ។ អាកប្បកិរិយារបស់មនុស្សត្រូវបានបង្កើតឡើងដោយទម្លាប់ដែលយើងជ្រើសរើសដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់ក្នុងជីវិត ហើយជាលទ្ធផលនៃការសិក្សាតាមទ្រឹស្តីលក្ខខណ្ឌ។

---

[10] University of Massachusetts Amherst (2002): https://scholarworks.umass.edu/entities/publication/4397ab85-a9c7-40f2-a7f3-1b078b1ade20
[11] ITpedia (2011): https://km.itpedia.nl/2011/03/28/algemene-voorwaarden/
[12] Lawyers (December 10,2019): https://www.khsearch.com/qna/27372
[13] ITpedia (2011): https://km.itpedia.nl/2011/03/28/algemene-voorwaarden/

ទ្រឹស្ដីលក្ខខណ្ឌនៃការរៀនមានពីរប្រភេទសំខាន់ៗគឺ ទ្រឹស្ដីការដាក់លក្ខខណ្ឌបែបបុរាណ និងទ្រឹស្ដីលក្ខខណ្ឌប្រតិបត្តិការ។ ឥឡូវយើងដឹងថាអ្វីទៅជាលក្ខខណ្ឌនៃការរៀនសូត្រ សូមមើលប្រភេទនីមួយៗនៃពីរយ៉ាងលម្អិត។

ទ្រឹស្ដីលក្ខខណ្ឌបែបបុរាណនិយាយថាការរៀនកើតឡើងនៅពេលដែលការជំរុញធម្មជាតិត្រូវបានផ្គូផ្គងនឹងការជំរុញអព្យាក្រឹតដើម្បីបង្កើតការឆ្លើយតប។ អ្នកជំនាញខាងសរីរវិទ្យាជនជាតិរុស្ស៊ី Ivan Pavlov គឺជាអ្នកបង្កើតទ្រឹស្ដីនៃការដាក់លក្ខខណ្ឌបែបបុរាណ។

នៅក្នុងការពិសោធន៍ដ៏ល្បីរបស់គាត់ជាមួយសត្វឆ្កែ Pavlov បានបន្លឺកណ្ដឹងមួយ មុនពេលផ្ដល់អាហារដល់សត្វឆ្កែ។ គាត់និយាយដដែលៗនេះច្រើនដង ដោយតែងតែផ្គូផ្គងសំឡេងកណ្ដឹងជាមួយអាហាររបស់ឆ្កែ។ នៅទីបំផុត ឆ្កែចាប់ផ្ដើមភ្ជាប់សំឡេងកណ្ដឹងជាមួយអាហារ។ គាត់ចាប់ផ្ដើមស្រក់ទឹកមាត់ដោយទន្ទឹងរង់ចាំអាហារភ្លាមៗ នៅពេលដែលគាត់បានលឺសំឡេងជួង សូម្បីតែអាហារមិនមានវត្តមានក៏ដោយ។

ត្រូវបានគេស្គាល់ផងដែរថាជា ការដាក់លក្ខខណ្ឌឧបករណ៍ ទ្រឹស្ដីនៃការដាក់លក្ខខណ្ឌប្រតិបត្តិការនិយាយថា ការរៀនសូត្រអភិវឌ្ឍតាមរយៈរង្វាន់ និងការដាក់ទណ្ឌកម្មសម្រាប់អាកប្បកិរិយាជាក់លាក់។ យោងទៅតាមទ្រឹស្ដីនេះ នៅពេលដែលសារពាង្គកាយមួយមានឥរិយាបទដែលនាំឱ្យទទួលបានរង្វាន់ នោះពួកគេទំនងជានឹងធ្វើឡើងវិញនូវអាកប្បកិរិយានោះនៅពេលអនាគត។ ស្រដៀងគ្នានេះដែរ អាកប្បកិរិយាដែលនាំទៅរកការដាក់ទណ្ឌកម្ម គឺទំនងជាមិនសូវកើតឡើងវិញទេ។

ទ្រឹស្ដីនៃការរៀនសូត្រតាមលក្ខខណ្ឌប្រតិបត្តិត្រូវបានកំណត់ដោយចិត្តវិទូជនជាតិអាមេរិក B.F. Skinner ដែលផ្អែកលើការងាររបស់គាត់លើច្បាប់ប្រសិទ្ធភាពរបស់ Edward Thorndike។ Skinner បានធ្វើការពិសោធន៍ជាមួយសត្វកណ្ដុរនៅក្នុងប្រអប់ Skinner។ ប្រអប់មានដងថ្លឹងដែលបញ្ចេញគ្រាប់អាហារពេលកំពុងចុច។ កណ្ដុរបានរកឃើញដងថ្លឹងនេះដោយចៃដន្យ ដោយភ្ជាប់វាជាមួយអាហារ និងរៀនចុចដងថ្លឹងដើម្បីទទួលអាហារ[14]។

## ២.៤ លក្ខខណ្ឌដែលក្រុមហ៊ុនធានារ៉ាប់រងបដិសេធទូទាត់សំណងជូនអតិថិជន

### ២.៤.១ និយមន័យសំណង

**សំណង** សំដៅលើការខាតបង់ ឬការទទួលខុសត្រូវ។ សំណងជាច្រើនត្រូវបានបង្កើតឡើងដោយកិច្ចសន្យាមួយ ដែលរដ្ឋាភិបាលប្រទេសម្ចាស់ផ្ទះ អ្នកអភិវឌ្ឍន៍ អ្នកម៉ៅការ ឬភាគីពាក់ព័ន្ធផ្សេងទៀតសន្យាថានឹងបង់ការខាតបង់ដែលបានកំណត់អត្តសញ្ញាណ[15]។

**សំណង** សំដៅលើការទូទាត់ជារូបិយវត្ថុដែលបានផ្ដល់ឱ្យបុគ្គលម្នាក់ជាថ្នូរនឹងសេវាកម្មរបស់ពួកគេ។

**សំណង** សំដៅដល់អ្វីដែលនិយោជិតទទួលបាននៅកន្លែងធ្វើការ វារាប់បញ្ចូលទាំងប្រាក់បៀវត្សរ៍ ឬប្រាក់ឈ្នួលបន្ថែមលើកម្រៃជើងសារ និងការលើកទឹកចិត្ត ឬអត្ថប្រយោជន៍ណាមួយដែលមកជាមួយមុខតំណែងរបស់និយោជិត។ និយោជិតដែលមានប្រាក់ខែក៏ដូចជាអ្នកប្រឹក្សាខាងក្រៅឬបណ្ដោះអាសន្នមានសិទ្ធិទទួលបានសំណងមានន័យថាបុគ្គលនោះនឹងត្រូវបានបង់សម្រាប់ផលិតផល ឬសេវាកម្មដែលពួកគេផ្ដល់។

---

14 HARAPPA (September 09, 2021): https://harappa.education/harappa-diaries/conditioning-theory-of-learning/

15 ASIA SOCIETY POLICY INSTITUTE (2022): https://asiasociety.org/km/policy-institute/navigating-belt-road-initiative-toolkit/g l o ssary /hirnynyvtthu/indemnity-smnnng

និយមន័យសំណងដ៏ទូលំទូលាយរួមមានប្រាក់ជំពាក់ជាសំណងដល់ភាគីដែលរងរបួស ឬខុសផ្សេងទៀតដោយភាគីទទួលខុសត្រូវ[16]។

**សំណង** អាចត្រូវបានគេយល់ថាជាទម្រង់ផ្សេងគ្នានៃការត្រឡប់មកវិញដែលនិយោជិតទទួលបានជាផ្នែកនៃកិច្ចព្រមព្រៀងការងារ នេះរួមបញ្ចូលទាំងការត្រឡប់មកវិញផ្នែកហិរញ្ញវត្ថុ សេវាកម្ម និងអត្ថប្រយោជន៍ដូចជាការធានារ៉ាប់រង វិស្សមកាលដែលបានបង់ ថ្ងៃឈឺ គម្រោងប្រាក់សោធននិវត្តន៍ ការបញ្ចុះតម្លៃបុគ្គលិក និងច្រើនទៀត[17]។

**សំណង** មានន័យថា បង្កើតសម្រាប់អ្វីមួយ។ នៅពេលដែលភោជនីយដ្ឋានផ្តល់ឱ្យអ្នកនូវបង្អែមដោយឥតគិតថ្លៃជាសំណងសម្រាប់ការធ្វើឱ្យរញ៉េរញ៉ៃការបញ្ជាទិញអាហារពេលល្ងាចរបស់អ្នក ក្តីសង្ឃឹមគឺថាអ្នកនឹងរីករាយ (ហើយបដិសេធមិនសរសេរការពិនិត្យអវិជ្ជមានលើអ៊ីនធឺណិត) ។

**សំណង** ក៏អាចជាលុយដែរ ការទូទាត់មានន័យថាផ្តល់ឱ្យនរណាម្នាក់នូវការផ្លាស់ប្តូរដោយយុត្តិធម៌សម្រាប់ការខិតខំប្រឹងប្រែង និងលទ្ធផលរបស់ពួកគេ[18]។

**២.៤.២ ប្រវត្តិសំណង**

ពាក្យ សំណង មកពីពាក្យឡាតាំង compensare មានន័យថា ថ្លឹងទម្ងន់របស់អ្វីមួយទល់នឹងរឿងមួយទៀត។ វាក៏មកពីពាក្យឡាតាំង compensatio ដែលសំដៅទៅលើតុល្យភាព ឬការផ្លាស់ប្តូរវិធានការ ឬតម្លៃស្មើគ្នា។ បុព្វបទ com- មានន័យថា រួមគ្នាជាមួយ និងpensare មានន័យថា ថ្លឹងថ្លែង ដូច្នេះ សំណងសំដៅលើការបង់ប្រាក់ ឬរង្វាន់ដែលផ្តល់ឱ្យនរណាម្នាក់សម្រាប់ការងារដែលពួកគេបានធ្វើ ឬការបាត់បង់ដែលពួកគេបានទទួលរង[19]។

**២.៤.៣ សំណង**

តាមទស្សនៈសីលធម៌មុខងារនៃសំណងគឺត្រង់។ សំណងបម្រើដល់ការកែតម្រូវនូវអ្វីដែលត្រូវរាប់ថាជាការខូចខាតខុសចំពោះបុគ្គល ឬទ្រព្យសម្បត្តិរបស់ពួកគេ។ នោះគឺជាតួនាទីនៃ សំណងការខូចខាត នៅក្នុងច្បាប់នៃទារុណកម្ម និងគ្រាន់តែជាសំណង សម្រាប់ការទទួលយកទ្រព្យសម្បត្តិឯកជនជាសាធារណៈ។ ហើយនោះជាអ្វីដែលអ្នកសេដ្ឋកិច្ចសុខុមាលភាពថ្មីបានពឹងផ្អែកលើនៅពេលដែលធ្វើឱ្យលទ្ធភាពនៃអ្នកទទួលផលប៉ះប៉ូវអ្នកចាញ់នូវវិធានការត្រឹមត្រូវនៃគោលនយោបាយដែលអាចអនុញ្ញាតបាន។

ទោះជាយ៉ាងណាក៏ដោយ វាជាការខុសក្នុងការសន្មតថាយើងជាសង្គមមួយអាចធ្វើអ្វីដែលយើងចូលចិត្តចំពោះមនុស្សបាន លុះត្រាតែយើងផ្តល់សំណងដល់ពួកគេសម្រាប់ការខាតបង់របស់ពួកគេ។ សំណុំរងនៃសកលលោកគោលនយោបាយដែលសំណើបែបនេះអនុវត្តបានត្រឹមត្រូវ គោលនយោបាយដែល អនុញ្ញាតប៉ុន្តែបានតែជាមួយសំណង ត្រូវបានចងនៅម្ខាងដោយគោលនយោបាយដែលអាចអនុញ្ញាតបាន ទោះបីជាគ្មានសំណងក៏ដោយ និងម្ខាងទៀតដោយគោលនយោបាយដែលមិនអាចអនុញ្ញាតបាន ទោះបីជាមានសំណងក៏ដោយ។

ច្បាស់ណាស់មានរឿងមួយចំនួនដែលសង្គមយើងអាចធ្វើចំពោះមនុស្សដោយមិនផ្តល់សំណងដល់ពួកគេតាមមធ្យោបាយណាមួយសម្រាប់ការខាតបង់ជាបន្តបន្ទាប់របស់ពួកគេ។ រដ្ឋមិនចាំបាច់ផ្តល់សំណង

[16] Sage Group plc (2025): https://www.sage.com/en-us/blog/glossary/what-is-compensation/
[17] RHO (October 8, 2024): https://www.rho.co/blog/what-is-compensation
[18] Vocabulary.com: https://www.vocabulary.com/dictionary/compensation
[19] Yaktack (2025): https://yaktack.com/words/Compensation

ដល់ប្រជាជនដែលត្រូវបានបញ្ឈប់ពីការបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ សុវត្ថិភាព ឬសុខុមាលភាពនោះទេ។ គ្មាននរណាម្នាក់រំពឹងថាអធិការរដ្ឋនឹងផ្តល់សំណងទៅដល់ម្ចាស់ភោជនីយដ្ឋានគ្មានអនាម័យ ឬរោងចក្រគ្មានសុវត្ថិភាពដែលពួកគេបិទនោះទេ។ គ្មាននរណាម្នាក់នឹកស្មានថាភាពស្របច្បាប់នៃអាជ្ញាធរសុខភាពសាធារណៈដាក់ជនរងគ្រោះដោយជំងឺអុតស្វាយឱ្យនៅដាច់ដោយឡែកពីគេក្នុងមធ្យោបាយណាមួយដែលទាក់ទងនឹងសំណងដែលត្រូវបានបង់ឱ្យពួកគេសម្រាប់ប្រាក់ឈ្នួលដែលបាត់បង់នោះទេ[20]។

[20] Cambridge university press (January 28, 2010): https://www.cambridge.org/core/books/abs/utilitarianism-as-a-public-philosophy/theories-of-compensation/3943AA994076217D338C9D5014588BA5

# ជំពូកទី៣
# អត្ថប្រយោជន៍ដែលទទួលបានពីក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូន ឡាយហ្វ៍ អ៊ិនសួរេន ម.ក

## ៣.១ ស្ថានភាពទូទៅរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក

### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន

នៅឆ្នាំ១៩៨៨ ក្រុមអ្នកវិនិយោគជនជាតិតៃវ៉ាន់លោក Lawrence S.Ting’s បានចាប់ផ្តើមការវិនិយោគនៅទីក្រុងហូជីមិញ។ សព្វថ្ងៃ ទឹកប្រាក់ច្រើនជាង ៧៥០ លានដុល្លារ ត្រូវបានវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំៗហើយបានបង្កើតការងារផ្ទាល់ និងប្រយោលជាង ១០០,000 ការងារផងដែរ។

នៅឆ្នាំ២០០៤ បានចាប់ផ្តើមសាងសង់ទីក្រុង Phu My Hung ពីវាលភក់ទៅជាទីក្រុងទំនើបបំផុតមួយក្នុងប្រទេសវៀតណាម។ ជាលើកដំបូង ដែលមិនធ្លាប់មាននៅតំបន់អាស៊ីដែលបានទទួលពានរង្វាន់ “Horn Award for Urban Design” ដោយវិទ្យាស្ថានស្ថាបត្យករអាមេរិក។



នៅឆ្នាំ២០១៣ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត Phu Hung Life បានបើកដំណើរការជាផ្លូវការក្នុងឆ្នាំ ២០១៣។ Phu Hung Life គឺជាក្រុមហ៊ុនភាគហ៊ុនរួមដំបូងដែលបានប្រតិបត្តិការលើវិស័យធានារ៉ាប់រងអាយុជីវិតនៅក្នុងប្រទេសវៀតណាម។




នៅឆ្នាំ២០២០ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈុងឡាយហ្វ៍ ត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានផ្តល់អាជ្ញាប័ណ្ណប្រតិបត្តិការដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ ហ្វ៊ូឈុងឡាយហ្វ៍ ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត Phu Hung Life និងអ្នកឧកញ៉ា លី យុនថៃ ដែលជាប្រធានក្រុមហ៊ុន Alpha Group និងជាទីប្រឹក្សាផ្ទាល់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ហ្វ៊ូឈុងឡាយហ្វ៍ ជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅកម្ពុជា ដែលប្រតិបត្តិការតាមស្តង់ដារអន្តរជាតិ។ ថ្នាក់ដឹកនាំ និងគណៈគ្រប់គ្រងជាន់ខ្ពស់របស់ ហ្វ៊ូឈុងឡាយហ្វ៍ មានបទពិសោធន៍ក្នុងការបង្កើតក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតអន្តរជាតិ ដែលទទួលបានជោគជ័យនៅទូទាំងអាស៊ី ជាពិសេសនៅក្នុងទីផ្សារធានារ៉ាប់រងអាយុជីវិតថ្មីដែលកំពុងតែរីកចម្រើន ហើយក្រុមហ៊ុនក៏បាននាំជំនាញទាំងនេះមកប្រទេសកម្ពុជាដោយបង្កើតក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈុងឡាយហ្វ៍ នេះឡើង។ បទពិសោធន៍ដ៏សម្បូរបែបនេះ កើតចេញពីប្រធានក្រុមហ៊ុន លោក Graeme Hannah ដែលមានបទពិសោធន៍ជាង ៣០ ឆ្នាំក្នុងទីផ្សារធានារ៉ាប់រងអាយុជីវិតនៅទូទាំងអាស៊ី និងអឺរ៉ុប។ ភាពខ្លាំងនេះ ត្រូវបានពង្រឹងបន្ថែមដោយអ្នកឧកញ៉ា លី យុនថៃ ជាមួយនឹងចំណេះដឹងក្នុងស្រុកដ៏ស៊ីជម្រៅ និងបណ្តាញធុរកិច្ចដ៏ទូលំទូលាយរបស់លោកនៅទូទាំងប្រទេសកម្ពុជា។ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូឈុងឡាយហ្វ៍ ផ្តល់ជូននូវផលិតផលសន្សំ និងការពារ ទៅដល់អតិថិជន និងក្រុមគ្រួសារ តាមរយៈការផ្តល់សេវាបម្រើអតិថិជនលំដាប់ស្តង់ដារ។ ផលិតផលរបស់ ហ្វ៊ូឈុងឡាយហ្វ៍ គឺត្រូវបានរៀបចំឡើងជាពិសេសទៅតាមតម្រូវការហិរញ្ញវត្ថុរបស់ប្រជាជនកម្ពុជា ជាមួយនឹងតម្លៃដ៏សមរម្យបំផុត។




THE 雲極
GATEWAY

### ៣.១.២ និមិត្តសញ្ញារបស់ក្រុមហ៊ុន

Fortune
LIFE INSURANCE
Here for you, for life

### ៣.១.៣ ចក្ខុវិស័យ ការប្តេជ្ញាចិត្ត និងគុណតម្លៃរបស់ក្រុមហ៊ុន

➢ **ចក្ខុវិស័យ**

យើងខ្ញុំនឹងធ្វើឱ្យខ្លួនក្លាយជាក្រុមហ៊ុនដែលត្រូវបានទទួលស្គាល់ដោយអតិថិជន និងបុគ្គលិកថាជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដ៏ល្អបំផុតក្នុងប្រទេសកម្ពុជា។

➢ **ការប្តេជ្ញាចិត្ត**

- យើងខ្ញុំនឹងធ្វើឱ្យ ហ្វ័រឈូនឡាយហ្វ៍ ក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដែលមានការគាំទ្រច្រើននៅក្នុងប្រទេសកម្ពុជាដោយមានការណែនាំពីក្រុមគ្រួសារ និងមិត្តភក្តិ ព្រមទាំងទទួលបានការទុកចិត្តពីអតិថិជននៅក្នុងការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុដ៏ល្អ និងមានគុណភាព។
- យើងខ្ញុំជ្រើសរើស និងរក្សានូវបុគ្គលិកដែលមានទេពកោសល្យល្អៗ និងពូកែក្នុងទីផ្សារធានារ៉ាប់រងអាយុជីវិតក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន ហ្វ័រឈូនឡាយហ្វ៍ ផ្តល់ជូននូវការបណ្តុះបណ្តាល និងការអភិវឌ្ឍន៍ដល់បុគ្គលិកទាំងអស់របស់ខ្លួនដើម្បីជួយឱ្យពួកគេសម្រេចបាននូវគោលដៅផ្ទាល់ខ្លួនប្រកបដោយវិជ្ជាជីវៈ។
- យើងខ្ញុំផ្តល់ជូននូវ សុវត្ថិភាពការងារ រួមទាំងបរិយាកាសការងារល្អ។

➢ **គុណតម្លៃ**

គុណតម្លៃរបស់យើង បង្ហាញពីអត្តសញ្ញាណរបស់យើង បង្ហាញពីទង្វើដែលយើងប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក និងរបៀបដែលយើងធ្វើការប្រាស្រ័យទាក់ទងជាមួយអតិថិជនរបស់យើង៖

- យើងធ្វើការរួមគ្នាជាក្រុមតែមួយដើម្បីសម្រេចគោលដៅរបស់យើង
- យើងផ្តោតលើលទ្ធផលរបស់យើងជានិច្ច
- យើងទទួលយកភាពជាម្ចាស់ការលើការងាររបស់យើង និងការស្វះស្វែងរកវិធីដើម្បីសម្រេចគោលដៅរបស់យើង
- យើងមានសុជីវធម៌ ការគោរព និងការស្តាប់ចំពោះបុគ្គលិកគ្រប់ៗគ្នា
- យើងរៀនពីកំហុសរបស់យើង ហើយព្យាយាមយ៉ាងណាមិនឱ្យកើតឡើងម្តងទៀត
- យើងមិនស្តីបន្ទោសគ្នាទេ តែយើងស្វែងរកដំណោះស្រាយឱ្យគ្នាទៅវិញទៅមក
- យើងពិនិត្យរាល់ដំណើរការរបស់យើងជាប្រចាំដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន។

### ៣.១.៤ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន




## ៣.២ កត្តាដែលជម្រុញឱ្យអតិថិជនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនស្ទួរេន ម.ក

ការលក់ប័ណ្ណសន្យាធានារ៉ាប់រង គឺជាការលក់ពាក្យសន្យា ឬយើងអាចនិយាយបានថាជាការលក់ទំនុកចិត្ត ហេតុដូច្នេះហើយទំនុកចិត្ត គឺជារបស់ដ៏សំខាន់ណាស់នៃវិស័យមួយនេះ។

### ៣.២.១ ផលិតផលរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនស្ទួរេន ម.ក

គិតត្រឹមឆ្នាំ២០២៤ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ មានផលិតផលចំនួន៤ ដែលបាន នឹងកំពុងបំពេញតម្រូវការរបស់អតិថិជនគ្រប់ស្ថានភាពមិនថាអតិថិជននៅលីវ មានគ្រួសារ ឬនិយោជកទិញសម្រាប់ការពារនិយោជិត។

#### ក. ផលិតផលការសិក្សាជាមួយ ហ្វ័រឈូនឡាយហ្វ៍

ផលិតផលការសិក្សាជាមួយ ហ្វ័រឈូនឡាយហ្វ៍គឺជាផលិតផលមួយដែលជួយឱ្យអ្នកប្រើប្រាស់សន្សំប្រាក់សម្រាប់ការចំណាយលើថ្លៃសិក្សានៅវិទ្យាល័យឬសាកលវិទ្យាល័យរបស់កូន។

- ផ្តល់ជូនទឹកប្រាក់ត្រឡប់មកវិញខ្ពស់បំផុតដោយមានការធានា រហូតដល់ 110% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងដែលបានទិញ។
- អត្ថប្រយោជន៍នឹងត្រូវផ្តល់ជូនកូនដើម្បីបញ្ចប់ការសិក្សានៅវិទ្យាល័យ ឬសាកលវិទ្យាល័យ។
- អតិថិជនអាចរក្សាទុកអត្ថប្រយោជន៍ការសិក្សាដែលត្រូវបានធានាជាមួយ ហ្វ័រឈូនឡាយហ្វ៍ ដើម្បីបង្កើនការប្រាក់។
- ការបង់បុព្វលាភធានារ៉ាប់រងនឹងត្រូវបានលើកលែង ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងមានជំងឺធ្ងន់ធ្ងរ ពិការភាព ឬ ទទួលមរណភាព។

### ខ. ផលិតផលអនាគតគ្រួសារខ្ញុំជាមួយ ហ្វ៊ូវឈូនឡាយហ្វ៍

ផលិតផលមួយនេះ ផ្តល់ជូនអតិថិជននូវក្តីសុបិន្តសម្រាប់ខ្លួនឯង និងក្រុមគ្រួសារ ដែលជាគម្រោងសន្សំ និងការធានារ៉ាប់រងលើអាយុជីវិត ក្នុងកញ្ចប់តែមួយ។ ផលិតផលអនាគតគ្រួសារខ្ញុំជាមួយ ហ្វ៊ូវឈូនឡាយហ្វ៍ គឺជាផលិតផលដ៏ល្អឥតខ្ចោះ សម្រាប់អតិថិជនអ្នកប្រើប្រាស់ផ្ទាល់ និងគ្រួសារ។

- ផ្តល់ជូនទឹកប្រាក់ត្រឡប់មកវិញខ្ពស់បំផុតដោយមានការធានា រហូតដល់ 105% នៃចំនួនទឹកប្រាក់ដែលអតិថិជនបានបង់។
- ផ្តល់សំណង 100% នៃចំនួនទឹកប្រាក់ធានារ៉ាប់រង ប្រសិនបើអតិថិជនទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេលនៃការការពារ។
- ការបង់បុព្វលាភធានារ៉ាប់រងនឹងត្រូវបានលើកលែង ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងមានជំងឺធ្ងន់ធ្ងរ ពិការភាព ឬ ទទួលមរណភាព។

### គ. ផលិតផល For Life ចម្រើនទ្រព្យ

ជាផលិតផលពិសេសទ្វេដង សម្រាប់អតិថិជនដែលត្រូវការការការពារ និងការសន្សំក្នុងកញ្ចប់តែមួយ។ ផលិតផលនេះ ផ្តល់ជូនអត្ថប្រយោជន៍ខ្ពស់ ជាមួយបុព្វលាភធានារ៉ាប់រងសមរម្យបំផុត ហើយកាន់តែពិសេសជានាលើអត្ថប្រយោជន៍ដល់កាលកំណត់យ៉ាងជាក់លាក់ ទោះបីមាន ឬមិនមានរឿងអកុសលអ្វីកើតឡើងក៏ដោយ។

- ផ្តល់ជូនទឹកប្រាក់ត្រលប់តាមកាលកំណត់ 5% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងនៅចុងឆ្នាំទី៣ នៃផលិតផលនេះ ប្រសិនបើមិនមានការទាមទារសំណងលើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។
- ផ្តល់ជូនទឹកប្រាក់សំណង 100% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍។
- ក្នុងករណីដែលអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីមូលហេតុទូទៅត្រូវបានទូទាត់រួច ក្រុមហ៊ុនមិនតម្រូវឱ្យលោកអ្នកបង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ ប៉ុន្តែក្រុមហ៊ុននៅតែធានាទូទាត់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។
- ផ្តល់ជូនទឹកប្រាក់សំណងបន្ថែម 200% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងក្នុង ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់។
- ក្នុងករណីដែលអត្ថប្រយោជន៍មរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់ត្រូវបានទូទាត់រួច ក្រុមហ៊ុនមិនតម្រូវឱ្យលោកអ្នកបង់បុព្វលាភធានារ៉ាប់រងបន្តទៀតឡើយ ប៉ុន្តែក្រុមហ៊ុននៅតែធានាទូទាត់ជូនអត្ថប្រយោជន៍ដល់កាលកំណត់។
- ផ្តល់ជូនអត្ថប្រយោជន៍ដល់កាលកំណត់ 105% នៃចំនួនទឹកប្រាក់ធានារ៉ាប់រងដែលនឹងត្រូវទូទាត់ជូននៅកាលបរិច្ឆេទដល់កាលកំណត់នៃផលិតផលនេះ ដោយមិនអាស្រ័យថាអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍នោះឡើយ។

### ឃ. ផលិតផលការពារនិយោជិតជាមួយ ហ្វ៊ូវឈូនឡាយហ្វ៍

ជាផលិតផលមួយប្រភេទដែលផ្តោតសំខាន់លើម្ចាស់អាជីវកម្ម ប្រើប្រាស់សម្រាប់ផ្តល់ការធានារ៉ាប់រងអាយុជីវិតជូនដល់បុគ្គលិកដែលកំពុងបម្រើការងារក្នុងស្ថាប័នរបស់ខ្លួន។

- ការការពារដែលមានតម្លៃទាប និងទូទាត់ទឹកប្រាក់សរុបតែម្តងនៅក្នុងករណីដែលនិយោជិតជួបគ្រោះអកុសលណាមួយ។
- បង្កើនតម្លៃដល់ក្រុមហ៊ុន ក្នុងនាមជានិយោជកដែលមានទំនួលខុសត្រូវ និងផ្តល់ការយកចិត្តទុកដាក់ខ្ពស់លើនិយោជិត។
- និយោជិតអាចបំពេញការងារដោយភាពស្ងប់ចិត្ត ផលិតភាពការងារកើនឡើង និងអាចរក្សាបុគ្គលិកល្អៗដោយពួកគាត់មើលឃើញគុណតម្លៃរបស់ក្រុមហ៊ុន។

**៣.២.២ កត្តាសំខាន់ៗដែលជម្រុញឱ្យអតិថិជនប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិត**

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូរឈូនឡាយហ្វ៍ នឹងមិនអាចមានរូបរាងដូចសព្វថ្ងៃនេះបានឡើយ ប្រសិនបើគ្មានការទុកចិត្ត និងគាំទ្រពីសំណាក់អតិថិជនអ្នកប្រើប្រាស់ តែផ្ទុយទៅវិញព្រោះតែទំនុកចិត្ត និងភាពជឿជាក់របស់អតិថិជនបានធ្វើឱ្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមួយនេះ រីកចំរើនខ្លួនយ៉ាងឆាប់រហ័សហើយបានពង្រីកសាខាបុត្រសម្ព័ន្ធជាច្រើនពីវៀតណាម រហូតមកដល់កម្ពុជា។ ខាងក្រោមនេះគឺជាកត្តាដែលជម្រុញឱ្យអតិថិជនប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូរឈូនឡាយហ្វ៍៖

១. ក្រុមហ៊ុនហ្វ៊ូរឈូនឡាយហ្វ៍ ផ្តើមចេញពីក្រុមអ្នកវិនិយោគជនជាតិតៃវ៉ាន់លោក Lawrence S.Ting នៅប្រទេសវៀតណាមតាំងពីឆ្នាំ១៩៨៨ រហូតចូលមកដល់កម្ពុជានៅឆ្នាំ២០២០ ដោយត្រូវបានទទួលស្គាល់ និងផ្តល់អាជ្ញាប័ណ្ណប្រតិបត្តិការដោយក្រសួងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

២. ក្រុមហ៊ុនហ្វ៊ូរឈូនឡាយហ្វ៍ មានដៃគូរសហការជាមួយធនាគារ Cathay United Bank និងមន្ទីរពេទ្យស្ទើរតែគ្រប់បណ្តាខេត្តក្រុង និងរាជធានីក្នុងព្រះរាជាណាចក្រកម្ពុជា។

៣. គ្រប់បុគ្គលិករបស់ហ្វ៊ូរឈូនឡាយហ្វ៍សុទ្ធតែមានបទពិសោធន៍យ៉ាងជំនាញ ព្រមទាំងទទួលបានការបណ្តុះបណ្តាលបន្ថែមយ៉ាងតិចម្តងក្នុងមួយសប្តាហ៍ដើម្បីប្រាកដថាពួកគេពិតជាមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាមួយដ៏ល្អ ភាពជឿជាក់ ទំនុកចិត្ត និងសមស្របទៅតាមស្ថានភាពជាក់ស្តែងទៅកាន់អតិថិជន។

៤. ក្រុមហ៊ុនមានទីតាំងច្បាស់លាស់ ដើម្បីបង្កើនភាពងាយស្រួលដល់អតិថិជន បច្ចុប្បន្ន ហ្វ៊ូរឈូនឡាយហ្វ៍មានពីរទីតាំងគឺនៅរាជធានីភ្នំពេញ និងនៅទីរួមខេត្តកំពង់ធំ។

៥. ក្រុមហ៊ុនធ្វើការទូទាត់សំណងយ៉ាងឆាប់រហ័សជូនដល់សាច់ញាតិ និងក្រុមគ្រួសារដែលបានជួបហានិភ័យ ស្របតាមបណ្ណសន្យាដែលបានព្រមព្រៀង។

៦. ក្រុមហ៊ុនមានកំណើនអ្នកប្រើប្រាស់ច្រើនគួរឱ្យកត់សម្គាល់ តាមរយៈប្រតិបត្តិការអាជីវកម្មរៀងរាល់ថ្ងៃ។

៧. ក្រុមហ៊ុនបានចូលរួមសកម្មភាពសង្គមយ៉ាងសកម្មក្នុងកម្មវិធីសប្បុរសធម៌នានាដែលនាំឱ្យការផ្សព្វផ្សាយនៃសេកម្ម កាន់តែមានគុណភាព។

## ៣.៣ លក្ខខណ្ឌតម្រូវរបស់អតិថិជនមុនពេលដែលប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក

មុននឹងឈានដល់ការប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ បានត្រូវមានភាគីចូលរួមចំនួន២ មិនខ្វះបានឡើយគឺ អ្នកត្រូវបានធានា(Policyholder) និងអ្នកទទួលផល(Beneficiary)។

### ៣.៣.១ លក្ខខណ្ឌតម្រូវរបស់អ្នកត្រូវបានធានា (Policyholder)

រាល់គ្រប់ការបើកប្រកបអាជីវកម្មទាំងឡាយតែងមានបំណងចង់បានប្រាក់ចំណេញជាការតបស្នងត្រឡប់មកវិញ ចំណែកឯអតិថិជនគឺជាធាតុយ៉ាងសំខាន់មួយមិនអាចខ្វះបានឡើយនៅក្នុងអាជីវកម្មដើម្បីផលិតប្រាក់ចំណូល។ នេះអាចបញ្ជាក់ប្រាប់យើងបានថា អតិថិជនមានកាន់តែច្រើន នាំឱ្យក្រុមហ៊ុនអាចបង្កើតប្រាក់ចំណូលបានកាន់តែច្រើន។ ថ្វីបើអតិថិជនជាជង្គឹមនៃអាជីវកម្មក៏ពិតមែន តែបើក្រុមហ៊ុន ហ្វ័រឈូនឡាយហ្វ៍មិនបានយកចិត្តទុកដាក់ខ្ពស់លើការគោលការណ៍មួយចំនួនទេ នោះប្រាកដណាស់ថាស្ថាប័នហិរញ្ញវត្ថុមួយនេះនឹងមិនអាចជួយអតិថិជនរបស់ខ្លួនឱ្យមានសុវត្ថិភាពហិរញ្ញវត្ថុជាក់លាក់នោះទេក៏តែតែមិនអាចសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួនក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតដ៏ល្អបំផុតក្នុងប្រទេសកម្ពុជានេះបានដែរ។ ហេតុដូច្នេះសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ បានកំណត់ឱ្យមានគោលនយោបាយចំនួន៨ ដូចខាងក្រោមនេះ ដើម្បីអនុវត្ត និងសិក្សាស៊ីជម្រៅប្រកបដោយក្រមសីលធម៌ខ្ពស់ មុននឹងសម្រេចចិត្តថាតើគួរ ឬមិនគួរផ្តល់សេវាមួយនេះជូនដល់អតិថិជនរបស់ខ្លួន។

១. ទំនាក់ទំនងដែលអាចធានាបាន សំដៅដល់ទំនាក់ទំនងអ្នកត្រូវបានធានាលើអាយុជីវិត និងអ្នកទទួលផលគឺត្រូវតែជាប្តីប្រពន្ធ និងសាច់ញាត្តិបង្កើតតែប៉ុណ្ណោះ(ឪពុកម្តាយបង្កើត បងប្អូនបង្កើត និងកូនបង្កើត)។

២. ស្ថានភាពសុខភាព អតិថិជនគប្បីមានសុខភាពសមស្របទៅតាមគោលការកំណត់របស់ក្រុមហ៊ុន និងតម្រូវឱ្យមានអាយុចន្លោះចាប់ពី១៨ ដល់៦០ឆ្នាំ សម្រាប់អ្នកត្រូវបានធានាលើអាយុជីវិត។

៣. អាជីព/មុខរបរ ប្រភេទនៃមុខរបរដែលមានហានិភ័យខ្ពស់ក៏ជាកត្តាមួយសំខាន់ដែរដូចជា អ្នកដោះមីនអ្នកពន្លត់អគ្គីភ័យ ឬអ្នកប្រកបរបរកីឡាងាយគ្រោះថ្នាក់ជាដើម...។

៤. ស្ថានភាពហិរញ្ញវត្ថុ ត្រូវមានមុខរបរជាក់លាក់ និងស្ថេរភាពដើម្បីបញ្ជាក់ថាអតិថិជនពិតជាមានលទ្ធភាពបង់លើកញ្ចប់ទឹកប្រាក់ធានាដោយមិនប៉ះពាល់ដល់ចំណូលផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារប្រចាំថ្ងៃ។

៥. ទីកន្លែងស្នាក់នៅ អតិថិជនត្រូវតែមានទីលំនៅ និងប្រវត្តិទីកន្លែងធ្លាប់រស់នៅច្បាស់លាស់។

៦. របៀបរស់នៅ សំដៅដល់ទំលាប់ជាប្រចាំរបស់អតិថិជន ថាតើជាធម្មតាគាត់មានទំលាប់ដើរលេង ចូលចិត្តលេងកីឡា ឬចូលចិត្តធ្វើអ្វីដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតឬអត់។

៧. ច្បាប់ និងអនុលោមតាម ត្រូវប្រាកដថាអតិថិជនដែលមានបំណងចង់ទិញសេវា ត្រូវមានប្រវត្តិល្អ មិនធ្លាប់ប្រព្រឹត្តិបទល្មើសផ្សេងៗឡើយ។

៨. ច្បាប់ស្តីពីការអនុលោមតាមច្បាប់ពន្ធលើគណនីបរទេស (FATCA) សំដៅដល់បុគ្គលដែលមានសញ្ជាតិជាពលរដ្ឋអាមេរិក។ ពួកគេត្រូវបង្ហាញ និងបញ្ជាក់នូវរាល់ឯកសារពាក់ព័ន្ធទាំងឡាយ ឱ្យបានច្បាស់លាស់ មុននឹងឈានដល់ការសម្រេចចិត្តលក់ជូននូវបណ្ណសន្យាធានារ៉ាប់រងជូនអតិថិជនប្រភេទនេះ។

**៣.៣.២ លក្ខខណ្ឌតម្រូវរបស់អ្នកទទួលផល (Beneficiary)**

អ្នកទទួលផលដាច់ខាតត្រូវតែជាប្ដី ឬប្រពន្ធ ឬសាច់ញាត្តិបង្កើតតែប៉ុណ្ណោះ (ឪពុកម្ដាយបង្កើត បងប្អូនបង្កើត និងកូនបង្កើត)។ ជាទូទៅអ្នកទទួលផលមិនត្រូវបានកំណត់អាយុនោះទេ ហើយអ្នកត្រូវបានធានាអាចធ្វើការជ្រើសរើស ឬផ្លាស់ប្ដូរអ្នកទទួលផលបានទៅតាមកាលៈទេសៈជាក់ស្ដែងណាមួយ។

## ៣.៤ លក្ខខណ្ឌដែលក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ អ៊ិនសួរេន ម.ក បដិសេធទូទាត់សំណងជូនអតិថិជន

ជាធម្មតាការទូទាត់សំណងអាចកើតមានឡើងទៅបានលុះណាតែអតិថិជនជួបហានិភ័យ ឬដល់កាលកំណត់នៃរយៈពេលអស់សុពលភាពរបស់បណ្ណសន្យាធានារ៉ាប់រងមកដល់។ ហានិភ័យទីនេះគឺសំដៅដល់អតិថិជនបាត់បង់ជីវិត ឬពិការភាពទាំងស្រុង។ ចំណែកពាក្យពិការភាពទាំងស្រុងគឺមានន័យថា ស្លាប់មួយចំហៀងខ្លួន ឬទាំងស្រុង ឬបាត់បង់អវៈយវៈពីរក្នុងចំណោមអវៈយវៈទាំងប្រាំមួយនៃរាងកាយរួមមាន ដៃពីរ ជើងពីរ និងភ្នែកពីរ។ រីឯកញ្ចប់ទឹកប្រាក់សំណងគឺនឹងត្រូវបានទូទាត់ជូនអតិថិជនមិនឱ្យលើសពីប្រាំពីរថ្ងៃឡើយនៃថ្ងៃធ្វើការបន្ទាប់ពីអតិថិជន ឬសាច់ញាត្តិអតិថិជនបានផ្ដល់នូវរាល់ឯកសារពាក់ព័ន្ធមកបញ្ជាក់គ្រប់គ្រាន់ពីការទាមទារយកកញ្ចប់ទឹកប្រាក់សំណងដូចជា សំបុត្រមរណៈភាព សំបុត្របញ្ជាក់ពីស្ថានភាពរបស់អ្នកជំងឺឬបណ្ណសន្យាធានារ៉ាប់រងដែលដល់ថ្ងៃអស់សុពលភាពជាដើម។ ទោះជាយ៉ាងណាក៏នៅមានករណីមួយចំនួនដែលក្រុមហ៊ុនអាចនឹងបដិសេធទូទាត់សំណងផងដែរ ដែលករណីទាំងនោះមានដូចខាងក្រោម៖

**៣.៤.១ ករណីក្រុមហ៊ុនបដិសេធទូទាត់សំណងជូនអតិថិជន**

រាល់ពេលដែលអតិថិជនមានហានិភ័យមិនមែនមានន័យថាក្រុមហ៊ុនសុទ្ធតែត្រូវទូទាត់សំណងនោះទេ ក្រុមហ៊ុនត្រូវពិនិត្យមើលយ៉ាងលម្អិតទៅលើហានិភ័យនោះថាតើបណ្ដាលមកពីបញ្ហាអ្វីឱ្យប្រាកដ ក្នុងគោលបំណងយ៉ាងសំខាន់ដល់ការចូលរួមទប់ស្កាត់នូវសកម្មភាពប្រឆាំងសង្គមនានា។

១. ធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាតទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិបល្លាសក៏ដោយ។

២. ឆ្លងមេរោគហ៊ីវ(HIV) ឬជំងឺអេដស៍(AIDS) ឬជំងឺផ្សេងៗទៀតដែលពាក់ព័ន្ធ។

៣. ការប្រើប្រាស់នូវថ្នាំខុសច្បាប់នៅក្នុងកូទីត(narcotics) ថ្នាំរំញោច(stimulants) ឬសារជាតុញៀនដទៃទៀត។

៤. ទទួលទោសប្រហារជីវិត ឬចូលរួមក្នុងសកម្មភាពខុសច្បាប់ ឬប្រឆាំងនឹងការចាប់ខ្លួនរបស់អាជ្ញាធរ ឬសកម្មភាពលួចចេញពីពន្ធនាគារ ។

៥. សកម្មភាពខុសច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកទទួលផល ដែលរំលោភទៅនឹងបទបញ្ញត្តិនានាដូចដែលបានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជា។

៦. ពិការភាពកើតឡើងមុនកាលបរិច្ឆេទចាប់ផ្ដើមបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទបន្តសុពលភាពឡើងវិញ។

៧. សង្គ្រាម(ទោះមានឬមិនមានការប្រកាសជាមុន) សង្គ្រាមស៊ីវិល ឬជម្លោះប្រដាប់អាវុធផ្សេងៗ។

៨. ការបង្កគ្រោះថ្នាក់ដោយខ្លួនឯងរបស់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងទោះជាក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមានវិល្លាសក៏ដោយ។

៩. ចូលរួមក្នុងសកម្មភាពហោះហើរលើកលែងតែអ្នកដំណើរនៃអាកាសចរណ៍ស៊ីវិលដែលមានការវិភាគហោះហើរ។

១០. បម្រើការងារក្នុងជួរយោធាឬកងទ័ពជើងទឹកក្នុងកំឡុងពេលដែលមានសង្គ្រាម (ទោះមានឬមិនមាន)ការប្រកាសជាមុនឬនៅក្រោមបញ្ជានៃប្រតិបត្តិការសង្គ្រាម ឬការស្តារសណ្តាប់ធ្នាប់សាធារណៈ។

**៣.៤.២ ករណីលើកលែងអត្ថប្រយោជន៍បន្ថែមក្នុងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍បណ្តាលមកពីគ្រោះថ្នាក់**

ចំពោះផលិតផល For Life ចម្រើនទ្រព្យ បើអតិថិជនមានហានិភ័យដែលបណ្តាលមកពីគ្រោះថ្នាក់នោះក្រុមហ៊ុននឹងធ្វើការទូទាត់សំណងភ្លាមដល់អតិថិជន៣០០% នៃកញ្ចប់ទឹកប្រាក់គម្រោង ក៏ប៉ុន្តែក្រុមហ៊ុននឹងកាត់អត្ថប្រយោជន៍នេះ២០០% ចេញ ពោលគឺអតិថិជននឹងទទួលបានការទូទាត់សំណងត្រឹម១០០% ប៉ុណ្ណោះនៃកញ្ចប់ទឹកប្រាក់សំណងបើហានិភ័យនោះកើតឡើងដោយសារតែករណីដូចខាងក្រោម៖

១. ការស្នើសុំវះកាត់ដែលសំដៅដល់ការវះកាត់តាមនីតិវិធីក្បួនវេជ្ជសាស្ត្ររួមទាំងការវះកាត់កែសម្ផស្សដោយមិនចាំបាច់ឈរលើមូលដ្ឋានវេជ្ជសាស្ត្រឡើយដែលបានធ្វើឡើងតាមសំណើរបស់អ្នកត្រូវបានធានារ៉ាប់រង ឬម្ចាស់បណ្ណសន្យារ៉ាប់រងដែលស្ថិតក្រោមការការពាររបស់បណ្ណសន្យារ៉ាប់រងនេះ

២. អ្នកត្រូវបានធានាស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ស្រាបៀរ ដែលស្មើនិងបទបញ្ញត្តិច្បាប់ដែលមានចែងក្នុងច្បាប់កម្ពុជាជាធរមានឬថ្នាំដែលមិនមានបញ្ជាក់វេជ្ជបញ្ជាត្រឹមត្រូវ

៣. ការប៉ះពាល់ផ្នែករាងកាយ ឬផ្លូវចិត្ត ឬស្ថានភាពចុះខ្សោយ ឬភាពទ្រុឌទ្រោមដែលត្រូវបានបញ្ជាក់ថាបានកើតឡើងមុនពេលកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រងនេះដោយមិនត្រូវបានប្រកាសឲ្យបានពេញលេញ និងត្រឹមត្រូវ

៤. ចូលរួមក្នុងសកម្មភាពគ្រោះថ្នាក់រួមទាំងតែមិនកំណត់ចំពោះការប្រមុជទឹកការលោតខ្សែយោង ការលោតឆ័ត្រយោង ការឡើងភ្នំ ការប្រណាំងសេះ ឬការប្រណាំងផ្សេងទៀតដែលមានកង់រិល

៥. អាវុធនុយក្លេអ៊ែរ វិទ្យុសកម្ម ឬវិទ្យុសកម្មពីសារធាតុនុយក្លេអ៊ែរ ឬកាកសំណល់នុយក្លេអ៊ែរដែលកើតចេញពីចំហេះនៃសារធាតុនុយក្លេអ៊ែរ និងដំណើរការនៃការបែងចែក/ការលាយលុយក្លេអ៊ែរដើម្បីត្រង់ខ្លួនឯង

៦. ចូលរួមក្នុងសកម្មភាពវាយតប់ ការតស៊ូមតិ ឬឈរប្រឆាំងនឹងការចាប់ខ្លួនអាជ្ញាធរមានសមត្ថកិច្ច

៧. ផលវិបាកដែលទាក់ទងនឹងការមានផ្ទៃពោះ ឬការសម្រាលកូន។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំងនិង ចំណុចខ្សោយ

នៅក្នុងអាជីវកម្ម ឬក្រុមហ៊ុនមួយ តែងតែមាននូវចំណុចខ្លាំង និងចំណុចខ្សោយរៀងៗខ្លួនដែលជាកត្តាសំខាន់ជំរុញដល់ការវាយតម្លៃ ការសិក្សាពីឱកាស ហានិភ័យ និងការវាស់វែងពីសកម្មភាពដំណើរការនៃការវិវត្តន៍របស់ក្រុមហ៊ុន។ ក្រោយពីការសិក្សាស្រាវជ្រាវ និងវិភាគអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុនរួចមក ក្រុមយើងខ្ញុំសង្កេតឃើញថា មានចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ័រឈូនឡាយហ្វ៍ មានដូចខាងក្រោមៈ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- អតិថិជនប្រើប្រាស់សេវាយ៉ាងមានទំនុកចិត្តដោយផ្អែកទៅលើ កេរ្តិ៍ឈ្មោះ ទីតាំងច្បាស់លាស់ ដៃគូសហការណ៍ ផលិតផលមានច្រើនជម្រើស និងប្រវត្តិទូទាត់សំណង។
- ក្រុមហ៊ុនមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈដៃគូសហការណ៍ ប្រព័ន្ធអ៊ិនធឺណេត និងការផ្សព្វផ្សាយដោយផ្ទាល់តាមរយៈការចូលរួមសកម្មភាពសង្គម និងសកម្មភាពសប្បុរសធម៌នានា។
- គ្រប់បុគ្គលិកទាំងអស់សុទ្ធតែមានសមត្ថភាព ដោយទទួលបានការបណ្តុះបណ្តាលយ៉ាងស្ទាត់ជំនាញពីកម្មវិធីពង្រឹងសមត្ថភាពបុគ្គលិកជារៀងរាល់សប្តាហ៍។
- ទទួលបានអតិថិជនដែលមានសក្តានុពលដែលមានស្របលក្ខខណ្ឌ និងគោលការណ៍របស់ក្រុមហ៊ុន។
- អតិថិជនទទួលបានការប្រើប្រាស់សេវាចំគោលដៅផ្អែកតាមស្ថានភាពជាក់ស្តែងរបស់អតិថិជន។
- ទប់ស្កាត់នូវសកម្មភាពប្រឆាំងសង្គមដែលអតិថិជនជាអ្នកបង្ករឡើងដោយចេតនា។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- អតិថិជនមិនមានទំនុកចិត្តក្នុងការប្រើប្រាស់សេវាព្រោះអតិថិជននៅមានផ្នត់គំនិតថា ការទិញសេវាធានារ៉ាប់រងគឺជាការប្រមាថអាយុជីវិត។
- បាត់បង់អតិថិជនក្នុងករណីអតិថិជនមានលក្ខខណ្ឌតម្រូវមិនគ្រប់គ្រាន់ស្របតាមក្រុមហ៊ុន។
- ចំណាយពេលវេលាក្នុងការសិក្សាលើលក្ខខណ្ឌតម្រូវមុនពេលប្រើប្រាស់សេវា។
- មិនទទួលបានការទូទាត់សំណងពេលជួបហានិភ័យក្នុងករណីខុសលក្ខខណ្ឌ។
- បង្កការភាន់ច្រឡំរវាងអតិថិជន និងក្រុមហ៊ុន ពេលទាមទារសំណង។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការស្រាវជ្រាវតាំងពីជំពូកដំបូងមក យើងអាចធ្វើការសន្និដ្ឋានបានថា ក្រុមហ៊ុន ហ្វ៊ូរឈូនឡាយហ្វ៍ បានបម្រើសេវាកម្ម និងមានផលិតផលធានារ៉ាប់រងអាយុជីវិតជាច្រើនគួរឱ្យកត់សម្គាល់។ ក្រុមហ៊ុនកំពុងព្យាយាមយ៉ាងខ្លាំង និងប្រើប្រាស់រាល់គ្រប់មធ្យោបាយ ដើម្បីជម្រុញឱ្យអតិថិជនមានការជឿជាក់មកប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន ស្របពេលដែលក្រុមហ៊ុននឹងផ្តល់ជូនអតិថិជនវិញនូវអត្ថប្រយោជន៍ការការពារផ្នែកហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព។ អតិថិជនចូលមកប្រើប្រាស់សេវារបស់ក្រុមហ៊ុនគឺជាតម្រូវការសំខាន់ណាស់សម្រាប់អាជីវកម្មខ្លួន ក៏ប៉ុន្តែមិនមែនមានន័យថា ឱ្យតែអតិថិជនមានលុយសុទ្ធតែអាចប្រើប្រាស់សេវានេះបានទេ។ យ៉ាងណាមិញ មុននឹងអាចប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតរបស់ក្រុមហ៊ុន ហ្វ៊ូរឈូនឡាយហ៍ លុះត្រាតែអតិថិជនមានលក្ខខណ្ឌតម្រូវសមស្របទៅនឹងគោលការណ៍របស់ក្រុមហ៊ុនដូចគ្នា។ ការធ្វើបែបនេះ ក្រុមហ៊ុននឹងទទួលបានអតិថិជនដែលមានសក្តានុពល ហើយអតិថិជននឹងទទួលបានការប្រើប្រាស់សេវាចំគោលដៅផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ខ្លួនដូចគ្នា។ ក្រោយពីមានការគាំទ្រប្រើប្រាស់សេវាពីបណ្តាអតិថិជនយ៉ាងច្រើន ជាអកុសលក៏មានអតិថិជនមួយចំនួនតូចដែលបានទទួលរងនូវហានិភ័យហើយក្រុមហ៊ុនត្រូវធ្វើការទូទាត់សំណងជូនអតិថិជនទៅលក្ខខណ្ឌដែលបានចរចារ។ ទោះជាយ៉ាងណាក៏ដោយ មុននឹងធ្វើការទូទាត់សំណងនោះ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូរឈូនឡាយហ៍ នឹងពិនិត្យយ៉ាងលម្អិតទៅលើហានិភ័យដែលបានកើតឡើងនោះ ថាតើបណ្តាលមកពីមូលហេតុអ្វីឱ្យពិតប្រាកដមុននឹងឈានដល់ការទូទាត់សំណងបានជោគជ័យ។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវយ៉ាងលម្អិតពីចំណុចខ្លាំង និងចំណុចខ្សោយរួមបញ្ចូលជាមួយនឹងសេចក្តីសន្និដ្ឋានផងដែរ ក្រុមយើងខ្ញុំក៏មើលឃើញនូវភាពរីកចម្រើន និងដំណើរការអភិវឌ្ឍន៍ទៅមុខយ៉ាងរលូនរបស់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ហ្វ៊ូរឈូនឡាយហ៍ នៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែក្រុមយើងខ្ញុំក៏មានជាមតិយោបល់ក្នុងន័យស្ថាបនាលើចំណុចខ្វះខាតមួយចំនួនដែលគួរតែកែតម្រូវបន្ថែម ដែលអាចជួយជម្រុញឱ្យមានកំណើនអតិថិជនសក្តានុពល ប្រើប្រាស់សេវាកម្មកាន់តែច្រើនដោយមានទំនុកចិត្ត ដើម្បីឱ្យក្រុមហ៊ុនកាន់តែអភិវឌ្ឍន៍លូតលាស់ទៅមុខបន្ថែមទៀត ក្នុងគោលបំណងបំពេញផលប្រយោជន៍យ៉ាងមានប្រសិទ្ធភាពឱ្យគ្នាទៅវិញទៅមកទាំងអតិថិជន និងក្រុមហ៊ុន។ ចំនុចដែលត្រូវកែតម្រូវមានដូចខាងក្រោម៖

- ក្រុមហ៊ុនគួរតែពង្រីកការផ្សព្វផ្សាយ ឱ្យប្រជាជននៅប្រទេសកម្ពុជាបានយល់ដឹងពីសេវាធានារ៉ាប់រងអាយុជីវិតកាន់តែទូលំទូលាយ។
- ក្រុមហ៊ុនគួរពង្រឹងសមត្ថភាពបុគ្គលិកឱ្យកាន់តែមានគុណភាពដើម្បីជៀសវាងការពន្យល់ និងផ្តល់ព័ត៌មានធ្វើឱ្យអតិថិជនមានការភាន់ច្រឡំ ជាពិសេសទៅលើលក្ខខណ្ឌនៃការទូទាត់សំណង មិនត្រឹមតែអតិថិជនដែលជាអ្នកត្រូវបានធានានោះទេ ត្រូវធ្វើការពន្យល់ និងផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ទៅកាន់អ្នកទទួលផលផងដែរ។

# ឯកសារយោង


1. Linked in. Ecoinsoft Solution. (2023, July 20) *តើអ្វីទៅជាការធានារ៉ាប់រង ?* Retrieved October 20, 2025, from https://www.linkedin.com/pulse/តអវទជ-ករធនរបរង-ecoinsof
2. EUROLAB Laboratory Inc. (2020). *សេវាធានារ៉ាប់រង.* Retrieved October 20, 2025, from https://www.denetim.com/km/hizmetler/diger-hizmetler/sigorta/
3. Investopedia. Andrew Beattie. (2023, August 21). *Tracing the Evolution of Insurance: From Ancient Babylon to Modern Day*. Retrieved from https://www.investopedia.com/articles/08/history-of-insurance.asp
4. Manulife. (2023, September). *អំពីមេនូឡាយហ្វ៍ ខេមបូឌា* . Retrieved October 20, 2025 from https://www.manulife.com.kh/km/about-us/our-story/our-brand.html
5. Ministry of Information. វ៉ាង ភក្ដី. (2022, July 27). *វិស័យធានារ៉ាប់រង នឹងផ្តល់វិភាគទានដល់សេដ្ឋកិច្ចក្នុងអត្រា៥,៥% នៅឆ្នាំ២០៣០.* Retrieved from https://www.information.gov.kh/articles/81641
6. និយ័តករធានារ៉ាប់រងកម្ពុជា. (2021, November 021). *ច្បាប់ស្តីពីការធានារ៉ាប់រង.* Retrieved October 20, 2025, from https://irc.gov.kh/article?post=7c09d33b-1992-4954-8653-c099663ba779 (មាត្រា២៣, ២៦, ៣២, ៣៩, ៤៦ )
7. Cambridge Dictionary. *Service*. Retrieved October 20, 2025, from https://dictionary.cambridge.org/dictionary/english/service
8. Wikipedia. Andrew Beattie. (August 2023). *Service (economics)*. Retrieved October 20, 2025, from https://en.wikipedia.org/wiki/Service_(economics)
9. Wikipedia. (2021, November 23). *សេវាកម្ម*. Retrieved October 20, 2025, from https://km.wikipedia.org/wiki/សេវាកម្ម/
10. University of Massachusetts Amherst. Roberts, Chris; Young, Lisa; Johanson, Misty M.; Dolasinski, Mary Jo. (2002). *Theory of Service: The User Perspective.* Retrieved October 20, 2025, from https://scholarworks.umass.edu/entities/publication/4397ab85-a9c7-40f2-a7f3-1b078b1ade20
11. IT-Pedia. (2011). *លក្ខខណ្ឌនិងលក្ខខណ្ឌ*. Retrieved October 20, 2025, from https://km.itpedia.nl/2011/03/28/algemene-voorwaarden/
12. KHsearch. Lawyers. (2019, December 10). *តើអ្វីទៅជាលក្ខខណ្ឌ ?* Retrieved October 20, 2025, from https://www.khsearch.com/qna/27372
13. HARAPPA. (2021, September 09) *compensation.* Retrieved October 20, 2025, from https://harappa.education/harappa-diaries/conditioning-theory-of-learning/
14. Sage Group plc. (2025). *What is compensation?* Retrieved October 20, 2025, from https://www.sage.com/en-us/blog/glossary/what-is-compensation/
15. ASIA SOCIETY POLICY INSTITUTE (2022). *សំណង.* Retrieved October 20, 2025, from https://asiasociety.org/km/policy-institute/navigating-belt-road-initiative-toolkit/g l o ssary /hirnynyvtthu/indemnity-smnnng
16. RHO. Pia Mikhael. (2024, October 8). *What is compensation (definition and examples)?* Retrieved October 20, 2025, from https://www.rho.co/blog/what-is-compensation
17. Vocabulary.com. (n.d.). Compensation. In Vocabulary.com Dictionary. Retrieved October 20, 2025, from https://www.vocabulary.com/dictionary/compensation
18. Yaktack. (2025). *Compensation*. Retrieved October 20, 2025, from https://yaktack.com/words/Compensation
19. Cambridge university press. Robert E. Goodin. (2010, January 28). *Theories of compensation.* Retrieved October 20, 2025, from

https://www.cambridge.org/core/books/abs/utilitarianism-as-a-public-philosophy/theories-of-compensation/3943AA994076217D338C9D5014588BA5

# ឧបសម្ព័ន្ធ

- **សកម្មភាពស្នើសុំចុះដល់ទីតាំងផ្ទាល់តាមរយៈ E-mail**

Thesis Proposal_ Students Group from Vanda Institution ប្រអប់សារ ×

សុក្រ 24 មករា • 9:00 AM – 10:00 AM

## Thesis Proposal_ Students Group from Vanda Institution

Soklim Thorn (HR) - អ្នករៀបចំ
Chamnan Doeuk (HR), Channtheary Keo (TDD), Chira Nai (TDD) និង 3 នាក់ផ្សេងទៀត

**នៅលើ Google ប្រតិទិនរបស់អ្នក**
គ្មានព្រឹត្តិការណ៍ផ្សេងទៀតនៅថ្ងៃនេះទេ

បាទ/ចាស | ដាក់ស្នើពេលវេលាថ្មី | បញ្ចូលកំណត់ចំណាំ

**Soklim Thorn (HR)** <soklim.thorn@fortunelife.com.kh> 15 មករា 2025, 3:27 PM
ជូនចំពោះ: Channtheary, ខ្ញុំ, Pengben, Chamnan, Chira, Roatana

Dear Bong Roatana,

Thanks for your prompt support.

@Channtheary Keo (TDD)
I would like to share you the meeting scheduled here and also, copy here Mr. Sila who representative thesis team in a loop.

For further assistant and clarification please let me know.

Best regard,
Soklim Thorn (HR)

---

**From:** Roatana Chey (TDD) <roatana.chey@fortunelife.com.kh>
**Sent:** Wednesday, January 15, 2025 1:47 PM
**To:** Soklim Thorn (HR) <soklim.thorn@fortunelife.com.kh>; Channtheary Keo (TDD) <channtheary.keo@fortunelife.com.kh>; Chira Nai (TDD) <chira.nai@fortunelife.com.kh>
**Cc:** Pengben Ngor (HR) <pengben.ngor@fortunelife.com.kh>; Chamnan Doeuk (HR) <chamnan.doeuk@fortunelife.com.kh>
**Subject:** RE: Thesis Proposal_ Students Group from Vanda Institution

Dear Sister @Soklim Thorn (HR),

Per our verbal talked this morning regarding to this letter in attached. This proposed is OK with our team, confirmed with the proposed date and time.

Hi br @Channtheary Keo (TDD) As verbal talked to you, Pls support them as requested, appointment schedule on **Friday, 24 January 2025 from 9:00am to 10:00am.**
Hi br @Chira Nai (TDD), Pls back up Theary. Thanks!

Best regards,
Roatana

---

**From:** Soklim Thorn (HR) <soklim.thorn@fortunelife.com.kh>
**Sent:** Wednesday, January 15, 2025 1:41 PM
**To:** Roatana Chey (TDD) <roatana.chey@fortunelife.com.kh>
**Cc:** Pengben Ngor (HR) <pengben.ngor@fortunelife.com.kh>; Chamnan Doeuk (HR) <chamnan.doeuk@fortunelife.com.kh>; Channtheary Keo (TDD) <channtheary.keo@fortunelife.com.kh>
**Subject:** Thesis Proposal_ Students Group from Vanda Institution

Dear Bong Roatana,
I hope this email find you well.

We had received the thesis proposal from our Partner, Cathay Bank's staff Maosetung Branch who's currently studying at Vanda Institution. The thesis requested on the topic "**Life Insurance Benefit**", enclosed the attached of further detail, students list and questionnaire for the interview.

Sequel to the above request, we would like to seek for your support in providing the resource and interviewee in charge serving this topic. Additionally, the students would like to propose the appointment schedule on **Friday, 24 January 2025 from 9:00am to 10:00am.**

Please let us know if the proposed time is workable at your side and for further clarification or concern.

Best regard,
Soklim

**Soklim Thorn**
Senior Supervisor,
Employee Services

Fortune LIFE INSURANCE
*Here for you, for life*

a. The Gateway- 26th Floor, Russian Blvd (110), Sangkat Phsar Depo 3, Khan Toul Kork, Phnom Penh, Cambodia
t. +855 89 763 164
e. soklim.thorn@fortunelife.com.kh
w. www.fortunelife.com.kh

## Request On-side visit for Thesis Defense



**Sam Sila** <samsilaklasor168@gmail.com> អង្គារ 24 ធ្នូ 2024, 10:23 AM
ជូនចំពោះ: soklim.thorn

Dear Bong Soklim,

I would like to officially request that On-side visit to the company purposely for The Thesis Defense at VANDA INSTITUTE OF ACCOUNTING in topic of "The Benefit Received from FORTUNE LIFE INSURANCE PLC".

Please kindly check in my attached files resume for details.

Thank you in advance for your attention and I am looking forward to getting good information and getting an On-side visit as requested.

Best Regard,
Mr. Sam Sila
085/093 422 202

ឯកសារភ្ជាប់ 2 • បានស្កេនដោយ Gmail



Question.pdf



Proposal.pdf

# សំនួរ

# Questions

១- តើសេវាធានារ៉ាប់រងអាយុជីវិត មានន័យដូចម្តេច ?

1- What is Life Insurance?

២- តើអតិថិជនទទួលបានអត្ថប្រយោជន៍អ្វីខ្លះ នៅពេលប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិត ?

1- What are the benefits for customers when using life insurance services?

៣- តើតម្រូវឲ្យអតិថិជនមានលក្ខខណ្ឌ ឬ លក្ខណៈសម្បត្តិអ្វីខ្លះ ទើបអាចទិញកញ្ចប់ធានារ៉ាប់រងអាយុជីវិតបាន ?

3- What conditions or qualifications do customers need to be able to purchase a life insurance package?

៤- សូមធ្វើបទបង្ហាញលំអិត អំពីផលិតផលនីមួយៗដែលក្រុមហ៊ុនមានលក់ជូនអតិថិជន។

4- Please detailed presentation about each product that the company sells to customers.

- សកម្មភាពចុះទៅសិក្សាផ្ទាល់ដល់ក្រុមហ៊ុន






- សកម្មភាពការងារជាក្រុមជាមួយគ្រូដឹកនាំ និងគណៈកម្មការ





- **សកម្មភាពការពារសារណាសាកល្បង**





➢ **សកម្មភាពសង្គមរបស់ក្រុមហ៊ុន**






➢ **សកម្មភាពបណ្តុះបណ្តាលបុគ្គលិករបស់ក្រុមហ៊ុន**



